គ្នាកាន់តែឈឺផ្សារនៅពេលដែលបានដឹងថាម្នាក់ៗមានសេចក្ដីសោកស្ដាយចំពោះរូបគ្នា។

ហើយពិតណាស់វាបានធ្វើឲគ្នាកាន់តែស្លុតចិត្តនៅពេលដែលបានឃើញដានិត នាងកំពុងតែស្រែកទ្រហោយំអង្គុយនៅក្បែរសាកសព។ នាងផ្ងូតឈាមដែលកំពុងចេញនៅតាមមាត់របស់សពបណ្ដើរ យំអោបថើបបណ្ដើរ។

ឱព្រះជាម្ចាស់អើយ! ម្ដេចក៏ពីរនាក់គ្នាត្រូវព្រាត់គ្នាបែបនេះ? គ្នាពិតជាអាណិតដានិតណាស់ គ្នាទ្រហោយំម្នាក់ឯងនៅពេលដែលកំពុងមើលទិដ្ឋភាពទាំងនោះ។

នៅក្នុងរូបភាពដែលបានបង្ហាញដោយបុទមមកគ្នា គ្នាក៏បានឃើញពីការលំបាករបស់នាងដែលនាងមិនអាចគេង មិនញ៉ាំអ្វីទាល់តែសោះក្នុងកំឡុងពេលពិធីបុណ្យសពរបស់គ្នា។

គ្នាក៏ពិតជាអគុណរ៉ូណាស់ដែលបានខំមកជួយយាមនិងកំដរសពរបស់គ្នានៅពេលយប់ ទោះបើគេមានឆ្នាំផុងនិងគ្នាក៏ដោយ។ គេពិតជាមិត្តល្អណាស់សំរាប់ពួកយើង គេមិនបានខ្វាយខ្វល់ឬបារម្ភនិងមានគ្រោះអ្វីទេ។ ដោយសារតែការស្រលាញ់មិត្តភក្ដិ គេបានអត់ងងុយមកជួយមើលការខុសត្រូវក្នុងពិធីយ៉ាងសកម្ម។ អំពើល្អរបស់គេនេះវាបានធ្វើឲគ្នាមានការរំជួយចិត្តយ៉ាងខ្លាំង គ្នាពិតជាចង់រស់ម្ដងទៀតហើយទៅប្រាប់គេថា គ្នាចង់បានគេជាមិត្តភក្ដិរហូតអនាគតជាតិ។

ចំពោះរិទ្ធីវិញ គ្នាមិនប្រកាន់ទេ ទោះបើគេមិនបានមកក្បែរសពរបស់គ្នា ដោយសារតែគេខ្លាចរអារសាកសពរបស់គ្នានោះ។ តាមពិតទៅរិទ្ធីទេដែលខ្លាចខ្លួនរិទ្ធី។ ដូចដែរចាន់ណារិនឯងដឹងហើយថាគ្នាស្រលាញ់ពួកម៉ាកស្មើៗគ្នា ចំពោះរិទ្ធីគ្នាអាណិតស្រលាញ់លើសគេក្នុងចំណោមមិត្តភក្ដិយើងទាំងអស់។ រិទ្ធីបានធ្វើឲគ្នាអស់សង្ឃឹមនៅពេលដែលមិនមកមើលគ្នា ជាលើកចុងក្រោយនេះ។ ក្នុងរូបភាពដែលបានបញ្ជាំងនៃពិធីបុណ្យសព គ្នាក៏បានឃើញមិត្តភក្ដិ រួមការងារជាច្រើននាក់ក៏បានមកចូលរួមនៅក្នុងពិធីនេះដែរ។ ជាការពិតដែលគ្នាស្ដាយខ្លួននៅពេលដែលឃើញគេលើកគ្នាដាក់ចូលទៅក្នុងម្ឈូស ហើយបានដង្ហែរយកមកបញ្ចុះ នៅក្នុងចេតិយ វត្តសុភាឃួននៅក្បែរព្រលានយន្តហោះពោចិនតុងនោះ។ តាមរយៈការបង្ហាញរូបភាពរបស់ បុទមវត្តី គ្នាក៏បានឃើញផងដែរសារ៉េតដែលកំពុងតែដេកព្យាលបាលនៅក្នុងមន្ទីពេទ្យកាល់ម៉ែត។ គ្នាដឹងថាសារ៉េតបានបាក់ជើង និងត្រូវរបួសយ៉ាងទំងន់ ហើយគ្នាពិតជាអាណិតគេណាស់ មិនគួរណាមកមានរឿងបែបនេះទេ ទោះយ៉ាងណាគ្នាក៏មាន សេចក្ដីសប្បាយរីករាយនៅក្នុងចិត្តផងដែរ





ព្រោះតែគេនៅមានជីវិតរស់នៅ។

ចាន់ណារិនមិត្តសំលាញ់ គ្នាសង្ឃឹមថាពួកម៉ាកឯងនិងមិនធុញទ្រាន់និងការអានសំបុត្ររបស់គ្នាដែលកំពុងតែនិយាយពីអ្វីដែលជាការពិត ការពិតដែលបានកើតឡើងចំពោះរូបគ្នា ក្រោយពីពេលដែលគ្នាបានលាពីឋានមនុស្សលោក។

នេះជាលើកដំបូងបង្អស់ដែលគ្នាសរសេរវែងទៅសំលាញ់ឯង ហើយគ្នាក៏គិតថាវាជាលើកចុងក្រោយដែរ ដែលគ្នាសរសេរទៅប្រាប់ពួកម៉ាកឯងក៏ដូចជាមិត្តភក្ដិឯទៀត។ គ្នាចង់បន្តសរសេរទៅទៀត ចង់បន្តដើម្បីប្រាប់ពួកម៉ាកឯងឲបានដឹងនូវអ្វីដែលបានកើតឡើងជាបន្ទាប់។

ពេលមួយដែលគ្នាកំពុងតែអង្គុយមើលទៅទឹកសមុទ្រ នឹកគិតទៅដល់អនុស្សាវរីយ៍ដែលយើងទាំងបួននាក់មាន ចាន់ណារិនឯង ដាតា ដានិតនិងគ្នាបានទៅលេងនៅឯក្រុងព្រះសីហនុនោះ ស្រាប់តែបុទមដែលមានសំលៀកបំពាក់ជារ៉ូបពណ៌ស បានមកជិតគ្នាដោយដំណើរថ្នមៗ

**«បងដឹងទេថាថ្ងៃនេះជាថ្ងៃទី៧ហើយណា៎! បងអាចទៅលេងអ្នកដែលបងចង់ជួបហើយ»**

គ្រាន់តែលឺពាក្យនេះភ្លាមគ្នាបានក្រលេកមកមើលម្ចាស់សំលេងទាំងសេចក្ដីត្រេកអរ ហើយបានពោលទាំងមិនដឹងខ្លួនថា៖

**«មែនឬ? តោះជូនខ្ញុំទៅ»**

**«បានបង តែដំបូងបងត្រូវងូតទឹកសំអាតក្លិនឆ្អេះឆ្អាបរបស់ជាតិជាមនុស្សសិន និងប្ដូរសំលៀកបំពាក់ទើបបងអាចចេញទៅបាន»**

**«ឥចឹងក៏បានតោះជួយជូនខ្ញុំទៅងូតទឹក»** គ្នានិយាយមិនរុញរា

ពួកនាងទាំងពីរបាននាំគ្នាមកកាន់អាងទឹកមួយដ៏ធំនៅលើកចាល់។ នៅក្នុងអាងនោះ មើលទៅមានផ្កាឈូកដុះអណ្ដែតពាសពេញផ្ទៃទឹក វាហាក់បីដូចជាអាងធម្មតាតែនៅពេលដែលគ្នាបានចុះចូលទៅក្នុងអាងនោះភ្លាម វាជាអាងដែលមានទឹកត្រជាក់ស្រិប ហើយមានក្លិនមិនខុសពីទឹកអប់ឡើយ។ គ្នាងូត គ្នាលុបមុខ និងបានដុសលាងប្រាណមួយសន្ទុះ ។ នៅក្នុងអាងនោះពិតជាមានសេចក្ដីសុខណាស់ វាបានធ្វើឲអារម្មណ៍របស់គ្នាបានធូស្រាលពីទុក្ខព្រួយទាំងឡាយ គ្នាមិន

ចង់ដើបទេតែដោយសារតែបុទមវត្តីប្រាប់ ទើបគ្នាព្រមដើបឲពួកនាងបំពាក់នូវឯកសណ្ឋានពិសេសនៃភពថ្មី។

សំលៀកបំពាក់នោះវាមិនខុសពីពួកនាងនោះទេ គ្នាត្រូវស្លៀករ៉ូបនិងទទួរស្បៃដ៏ទន់ល្មើយពណ៌ស នៅលើក្បាល។ នៅពេលដែលសំលៀកបំពាក់នោះបានមកប៉ះនិងស្បែកគ្នាភ្លាម វាបានធ្វើឲអារម្មណ៍របស់គ្នាកាន់តែរសាយ រំភើបនៅក្នុងចិត្ត។ គ្នាហាក់បីដូចជាបាននិងកំពុងប៉ះនិងពពកទាំងពួងដែលកំពុងតែហោះហើរនៅលើវេហាស៍។ ក្រណាត់ស្បៃនោះពិតជារលោង ត្រជាក់និងមានក្លិនដ៏ប្រហើរដ៏ក្រអូបឈ្ងុយឈ្ងប់។នៅពេលដែលវត្តីកំពុងតែចងខ្សែរក្រវ៉ាត់ឲគ្នានោះបុទមបានលាបាតដៃរបស់នាងយកមើលហើយនិយាយពីកម្មវិធីរបស់គ្នាមកថា៖

«បន្តិចទៀតនេះ បងនិងបានទៅលេងអ្នកដែលបងចង់ទៅជួប ហើយនៅពេលដែលបងត្រលប់មកវិញ បងនិងមិនមកកបាល់នេះទៀតទេ បងនិងត្រូវទៅគាល់ស្តេចយមរាជនៅឯឋាននរកដើម្បីទទួលផែនការបន្ត»

នៅពេលដែលគ្នាបានលឺការរៀបរាប់របស់នាងភ្លាម ការសប្បាយដែលនិងបានទៅជួបគ្រួសារបានរលាយហើយគ្នាបែរទៅជាមានការភ័យខ្លាចទៅវិញ។ គ្នាបានសួរទៅនាងថា៖

«ថាម៉េចស្តេចយមរាជ? ហេតុអ្វី?»

«សូមបងកុំមានការបារម្ភអ្វី គ្រប់គ្នាដែលបានស្លាប់គឺត្រូវចុះទៅកាត់ក្តីនៅឋានក្រោមមុននឹងចេញទៅកើតនៅឋានណាមួយទៀត។ វាគឺជាក្រិតក្រមនៅក្នុងវាលវដ្តសង្សារដ៏ធំនេះ។ តែបងកុំភ័យឲសោះ បងប្រហែលជាមិនមានបាបទេ ទើបស្តេចយមរាជហៅទៅគាល់ដោយអង្គឯងដូចនេះ។ បើមិនដូចនេះទេនោះបងមិនមានពួកខ្ញុំមកតាមបំរើឡើយ បងប្រហែលជាត្រូវចូលទៅក្នុងគុគនៅក្នុងឋាននរកទៅហើយ ហើយនៅពេលនេះក៏ប្រហែលជាកំពុងទទួលទារុណកម្មផងមិនដឹង» នាងនិយាយទាំងសើចញឹមៗ

យូរណាស់មកហើយដែលគ្នាមិនដែលបានឃើញស្នាមញញឹមរបស់នាង ទើបតែពេលនេះភាពញញឹមដ៏ស្រស់ស្រាយ បានបង្ហាញនូវបបេរមាត់ដ៏មានមន្តស្នេហ៍របស់អ្នកទាំងពីរ។ ឃើញគ្នានៅស្ងៀមដូចនេះ វត្តីបានបន្តទៅទៀតថា៖

«សូមបងកុំភ័យមើល!ទុកចិត្តមកលើពួកយើង គ្មានអ្វីនឹងកើតឡើងនោះទេ បងបានមកដល់





ភាពសុខសាន្តហើយ!»

គ្នានៅបន្តការស្ងៀមស្ងាត់ តែនៅក្នុងខ្លួនរបស់គ្នា ពិតជាញ័រភ័យខ្លាចជាអនេក នូវអ្វីដែលនាងបាននិយាយទាំងនេះ។ គ្នាបែរទៅស្រម៉ៃថាគ្នាធ្លាប់តែលឺគេនិយាយនៅឋានមនុស្សលោក ថាមានស្តេចយមរាជតែពេលនេះវាជាការពិតមែន។

«តោះបងដល់វេលាហើយ!» បុទមពោល

នាងទាំងពីរបានចាប់ដៃរបស់គ្នាម្ខាងម្នាក់ ស្រាប់តែពេលនោះគ្នាមានអារម្មណ៍ថាខ្លួនរបស់គ្នាបានរសាត់ហើបចេញពីកបាល់សន្សើមៗមកខាងលើនៃផ្ទៃអាកាស។គ្នាខំអើតទៅក្រោម កបាល់កាន់តែតូចទៅៗ ព្រោះតែពួកយើងកាន់តែហោះខ្ពស់ឡើងៗ។ នៅទីបំផុតគ្នាលែងឃើញស្រមោលកបាល់ដ៏កំសត់របស់គ្នាទៅទៀតហើយ គ្នាឃើញតែភាពសស្គុសនៅជុំវិញខ្លួនប្រាណរបស់គ្នា។ គ្នាខំដកដង្ហើមយ៉ាងធំ មួយៗ ហើយខិតខំកាត់ចិត្តបំភ្លេចនូវរឿងរ៉ាវទាំងប៉ុន្មានរំពេចនោះភាពសស្គុសបានប្រែក្លាយទៅជាភាពខ្មៅងងឹតទៅវិញ នៅពេលដែលគ្នាបានមកដល់មុខផ្ទះមួយដែល គ្នាមិនអាចចំណាំបានថាជាមុខផ្ទះរបស់ គ្នា។ បុទមវត្តីបានលែងដៃរបស់គ្នាទាំងពីរព្រមគ្នាហើយនិយាយឡើងថា៖

«ពេលនេះបងអាចចូលទៅលេងក្រុមគ្រួសារបងបានហើយ តែអូនសូមផ្តាំបងថា នៅមុនមាន់រងាវ៥ដង ឬនៅមុនម៉ោង៥ភ្លឺ បងត្រូវហៅឈ្មោះ «បុទមវត្តី» ព្រោះបងត្រូវត្រលប់ទៅជួបស្តេចយមរាជ ហើយម្យ៉ាងបងមិនអាចទទួលពន្លឺថ្ងៃទៀតទេ បើមិនដូចនោះទេមានន័យថានៅពេលដែលមានពន្លឺថ្ងៃប៉ះត្រូវសាច់របស់បង កុំថាបងមានស្បៃមន្តការពារ តោះបងមានបុណ្យប៉ុណ្ណាក៏ដោយ រូបបងនិងរលាយចេញពីលោកនេះមិនខាន ហើយក៏គ្មានដួងព្រលឹងបងនៅសេសសល់ទៀតទេ។»

«បងចាំដែរឬទេ?» វត្តីបន្ថែមទាំងទឹកមុខបារម្ភ

គ្នាបានងក់ក្បាលទទួលយល់ព្រម ហើយនៅពេលដំណាលគ្នានោះពួកគេបានរលាយបាត់ខ្លួនមួយរំពេចដូចជាផ្សែង។

នៅពីមុខផ្ទះតែម្នាក់ឯងដែលពេលនោះ គ្នាបានលឺសំលេងនាឡិកាបានវាយចំម៉ោង១២យប់

គត់។ គ្មាននរណាម្នាក់នៅជិតគ្នានោះទេ ឬ ក៏គ្មាននរណាធ្វើដំណើរទៅណាដែរ។ ចំណែកឯក្នុងផ្សារកណ្ដាលដែលនៅចំពីមុខផ្ទះគ្នា ហើយដែលតែងតែមានភាពអ៊ូអរនោះ តែពេលនេះស្រាប់តែមានសភាពស្ងាត់ជ្រងំដែលលឺតែសំលេងឆ្កែព្រូសគួរឲព្រឺឆ្អឹងខ្នងប៉ុណ្ណោះ ពួកវាទាំងនេះបានលូពីផ្ទះមួយទៅផ្ទះមួយដោយមិនចេះដាច់ទាល់តែសោះ។ ឆ្កែកាន់តែលូ វាបានធ្វើឲគ្នាកាន់តែហឹងស្លឹកត្រចៀក វាហាក់បីដូចជានរណាម្នាក់ដែលកំពុងតែមកដំបៅតផ្ទប់ និងត្រចៀករបស់គ្នាឥចឹង។

គ្នាក្រលេកមើលទៅឆ្វេងស្ដាំ គ្មាននរណាម្នាក់ទាល់តែសោះ គ្នាបានឈោងដៃទៅចុចកណ្ដឹងដែលនៅចំហៀងទ្វារម្ខាង គ្នាចុចមួយដងជាពីរដង តែគ្មានសមាជិកនៅក្នុងផ្ទះណាម្នាក់មកបើកទ្វារឲគ្នាឡើយ។ គ្នាខំប្រឹងចុចបន្តទៅទៀត នៅតែគ្មានប្រយោជន៍អ្វីទាំងអស់។ ដូច្នេះគ្នាបានត្រលប់មកចំកណ្ដាលទ្វារមុខផ្ទះវិញហើយអោនក្រលេកមើលតាមចន្លោះសោទៅខាងក្នុងផ្ទះ។ គ្នាបានឃើញថានៅទីនោះមានសភាពស្ងាត់ជ្រៀប និងងងឹតទៀតផង វាមានតែពន្លឺភ្លើងទានអគ្គីសនីពណ៌ក្រហមមួយដែលកំពុងតែបំភ្លឺឡឹមៗនៅចំកណ្ដាលផ្ទះ ដែលដាក់តាំងកំដរជីដូនជីតាប៉ុណ្ណោះ។

ដោយមិនមានអ្នកណាលឺឬក៏បើកទ្វារឲគ្នានោះ គ្នាក៏លូកដៃពីខាងក្រៅចូលទៅខាងក្នុង តាមចន្លោះទ្វារដ៏តូចមួយ ដើម្បីបើកសោ។ ជាការពិតដែលពេលនោះគ្នាពិតជាខ្លាចដៃខ្លួនឯងដែរ ព្រោះតែវាវែងជាងមុន វាអាចបត់បែនដូចជាសត្វពស់ ហើយលើសពីនោះទៀតវាអាច លូកចូលទៅខាងក្នុងដោយស្រួលទោះចន្លោះទ្វារតូចយ៉ាងណាក៏ដោយ។

កំពុងតែលូកដៃរៀបឆ្កឹះយកសោរចេញស្រាប់តែពេលនោះ មានដៃជ្រីវជ្រួញមួយបានចាប់គ្នាជាប់ហើយស្រែកយ៉ាងខ្លាំងចេញពីខាងក្នុងមកថា៖

«ពីណា?»

ពុទ្ធោ!នៅពេលនោះគ្នាពិតជាស្ទើរលស់ព្រលឹងទៅហើយ នៅពេលដែលទទួលសំលេងស្រែកដូចនោះ។ ដៃដ៏ត្រជាក់របស់គាត់បានធ្វើឲគ្នាមានអារម្មណ៍ញ័រនៅក្នុងបេះដូង។ គ្នាហាក់ដូចជាមិនស្គាល់និងចំណាំសំលេងនេះទេ ហើយថែមទាំងមិនដឹងថាជាអ្នកណាផង។ ទោះយ៉ាងណាគ្នាបានព្យាយាមតបទៅគាត់វិញថា៖





«ខ្ញុំកាណាអ៊ំស្រី!»

«អូរ! ចៅកាទេអី» គាត់បានតបដោយព្រមលែងដៃរបស់គ្នាមកខាងក្រៅវិញ កាលបើបានរួចដៃមកហើយឯគ្នាក៏ហាក់បីដូចជាបាត់ភ័យបន្តិច នៅពេលនោះដែរទ្វាផ្ទះបានបើកគ្រាំងដែលបានលេចចេញស្ត្រីចំណាស់ម្នាក់មានអាយុប្រមាណជា៧០ផ្លាយនៅឈរចំពីមុខគ្នា។ គ្នានៅស្ងៀមហើយខំប្រឹងគិតតែឯង នៅតែមិនស្គាល់ថាគាត់ជាអ្នកណាសោះ តែយ៉ាងណាគ្នាឆ្ងល់ខ្លួនឯងថា ហេតុអ្វីបានជាគាត់ស្គាល់រូបគ្នាដូចនេះ ហើយថ្មើរនេះស្ងាត់ឈឹងលឺសូរតែឆ្កែលូពីនាយវត្តឧណ្ណាលោម ម្ដេចក៏គាត់មិនចូលសំរាន្ត? គ្នាបានសួរទៅគាត់ភ្លាមថា៖

«តើលោកយាយអញ្ជើញមកពីណា? ហើយហេតុអ្វី បានជាលោកយាយបានមកដល់ផ្ទះរបស់ខ្ញុំ?»

«យាយបានត្រូវគេចាត់ឲមកនៅទីនេះដោយឲមកបំរើការពារម្ចាស់ផ្ទះ អស់ជាច្រើនឆ្នាំណាស់មកហើយ» គាត់និយាយបែបមនុស្សចាស់។

«លោកយាយមកបំរើនៅទីនេះ?ចុះហេតុអ្វីចៅមិនស្គាល់លោកយាយដូចនេះ?»

ឯងសួរទៅគាត់បែបឆ្ងល់

«ចៅកាមិនស្គាល់យាយទេ កាលពីចៅនៅរស់នោះ» គាត់គ្រវីក្បាល

«ពិតមែន?» គ្នាសួរបញ្ជាក់

«មែនណាចៅ» គាត់ងក់ក្បាលតិចៗ

«ឥចឹងមានតែលោកយាយជាជំនៀងផ្ទះមែនដែរឬទេ?»

«ត្រូវហើយ» គាត់ញញឹម

«ខ្ញុំយល់ហើយលោកយាយ» គ្នានិយាយបណ្ដើរងក់ក្បាលបណ្ដើរ បន្តិចមកគ្នាបានបន្តទៅទៀតថា៖

«ខ្ញុំមកទីនេះគឺមានបំណងចង់មកលេងផ្ទះរបស់ខ្ញុំ និងក្រុមគ្រួសារ សូមលោកយាយមេត្តាអនុញ្ញាត្តបើកផ្លូវឲចៅផង!» គ្នានិយាយដោយលំទោន

«វាមិនមែនផ្ទះរបស់ចៅទៀតទេ ចៅអស់ជាកម្មសិទ្ធនៅលើផ្ទះនេះទៀតហើយ ចៅបានស្លាប់ទៅហើយ ចៅគួរតែទៅកាន់ភពរបស់ចៅ ចៅមិនគួរមកវីរវល់និងបញ្ហាមនុស្សលោក

ទៀតនោះទេ» ជូនចាស់បានតបមកខ្ញាយ៉ាងមាំ

«លោកយាយខ្ញុំមិនចង់មានបញ្ហាអ្វីជាមួយលោកយាយនោះទេ វាមិនមែនផ្ទះរបស់ខ្ញុំមែនតែ វាជារបស់ទ្រព្យឪពុកម្ដាយខ្ញុំ ហើយក៏គ្មានន័យអ្វីដែលមិនមែនជារបស់ខ្ញុំដែរ»

ខ្ញានិយាយបែបខឹង ព្រមទាំងសំលេងខ្លាំង ហើយបន្តទៀតថា៖

«សូមលោកយាយមេត្តាបើកផ្លូវឲខ្ញុំ ខ្ញុំមិនដែលស្គាល់លោកយាយទេ»

«យើងមិនចេញទេយើងមាននាទីការពារអ្នកដែលរស់នៅទីនេះ បើចៅចង់ចូលលេង ចៅត្រូវមានក្រដាសអនុញ្ញាតពីឋានក្រោម» ជូនចាស់បានតបយ៉ាងម៉ឺងម៉ាត់

នៅពេលនោះខ្ញាពិតជាខឹងនិងសំដីរបស់គាត់ណាស់ ខ្ញាបានលោតហោះគេចចេញពីមុខគាត់ តែត្រូវគាត់ហោះមកបង្អាក់ផ្លូវរបស់ខ្ញា។ ខ្ញាបានបង្ហោះខ្លួនម្ដងទៀត គាត់ក៏នៅតែមកឃាំងពីមុខខ្ញាមិនឲចូល។ មួយដងជាពីរដង គាត់នៅតែមិនព្រមឲខ្ញាចូល ក្នុងសភាពបែបនេះខ្ញាពិតជាខឹងនិងគាត់យ៉ាងខ្លាំង ហើយមិនអាចឲខ្ញាទប់ទៀតបាន។ ខ្ញាបានយកដៃទៅគ្រវៀសគាត់ចេញពីមុខតែពេលនោះ នៅពេលដែលបានប៉ះសាច់របស់ជូនចាស់ភ្លាម ខ្លួនប្រាណរបស់ខ្ញាបានខ្ទៀតដូចជាដុំថ្មដែលត្រូវគេគ្រវាត់។ មើលមកដៃរបស់ខ្ញាវិញ វាចាប់ផ្ដើមរលួយដូចជាត្រូវទឹកអាស៊ីត។ ខ្ញាបានដួលទៅម្ខាងយ៉ាងសេចក្ដីឈឺចាប់ជាទីបំផុត។ កាលបើមានការឈឺចាប់ ដូចនេះហើយ វាបានធ្វើឲខ្ញាកាន់តែខឹងឡើងៗ ខ្ញាបានខំហោះទៅបំបុកខ្លោងទ្វារផ្ទះចូលម្ដងទៀត តែត្រូវមានសំណាញ់ភ្លើងមួយបានបាំងមិនឲខ្ញាចូលបាន ហើយតបមកខ្ញាវិញនៅ ការខ្ទៀតមកខាងក្រៅសារជាថ្មី។ លើកនេះខ្ញាបានដួលត្រលប់ត្រឡិន ហើយលើកនេះវាកាន់តែធ្ងន់ធ្ងរជាងមុនទៅទៀត។ ខ្ញាអត់កំលាំងហោះចូលម្ដងទៀតទេ ខ្ញាអង្គុយនៅមួយកន្លែងសំលឹងមើលមកដៃជើងខ្លួនប្រាណរបស់ខ្ញា។ ពេលនេះវាកំពុងតែមាន ពពុះនិងហូរឈាមឲកក្លាក់គួរឲខ្ពើមពេកកន្លង។ ខ្ញាពិតជាមានការឈឺចាប់ណាស់ ខ្ញាយំ ខ្ញាស្រែក ហើយប្រឹងទៅអង្វរជូនចាស់វិញសូមឲគាត់មេត្តាខ្ញាម្ដង។ ខ្ញានឹកគ្រួសាររបស់ខ្ញា ខ្ញាពិតជាចង់ ឃើញពួកគេសារជាថ្មី។ ខ្ញាបានទ្រហោយំស្របពេលជាមួយនិងសំលេងផ្គរលាន់និងខ្យល់បក់យ៉ាងខ្លាំង។ ខ្ញាបានអង្វរគាត់ឲខ្ញាបានចូលលើកនេះ នៅលើកក្រោយខ្ញានិងមានលិខិតអនុញ្ញាត្តមិនខាន។ ឃើញភាពវេទនារបស់ខ្ញាដូចនេះគាត់ក៏បាននិយាយឡើងថា៖





«បើចៅចូលទៅខាងក្នុង តើចៅហ៊ានសន្យាជាមួយយាយទេ ថាចៅនិងមិនធ្វើអ្វីឲខុសពីច្បាប់ភពថ្មីឡើយ?»

«បាទលោកយាយ ចៅសូមសន្យា! ខ្ញុំមិនធ្វើបាបអ្នកណាទាំងអស់»

ខ្ញានិយាយបណ្ដើរ ខ្ញាយំបណ្ដើរទាំងអង្គុយឈឺផ្សារពេកក្រៃដោយសារតែសំណាញ់ភ្លើងរបស់ជូនចាស់។ ខ្ញាបានទ្រហោយំដោយលើកដៃដែលកំពុងតែរលួយទាំងសងខាងទៅសំពះអង្វរគាត់ឲខ្ញាបានចូលទៅយប់នេះ។

នៅទីបញ្ចប់ជូនចាស់ដែលជាជំនៀងផ្ទះនោះបានយល់ព្រមដោយបានដកសំណាញ់ដែកចេញ ហើយរូបគាត់ក៏បានរលាយនៅក្រោយពេលគាត់និយាយមកប្រាប់ខ្ញាថា៖

«សូមចៅរក្សារពាក្យសម្បថរបស់ចៅ»

«បាទលោកយាយ! បាទលោកយាយ!»

ក្រោយពីគាត់បានចាកចេញទៅ ខ្ញាខំងើបឡើងទាំងត្រដាបត្រដួស ទាំងដៃជើងនិងខ្លួនប្រាណឈឺផ្សារ។ ខ្ញាបានហោះចូលទៅខាងក្នុងផ្ទះ។

ពួកម៉ាកអើយ! នៅពេលនោះខ្ញាពិតជាមានការឈឺចាប់ណាស់ ខ្ញានៅតែយំព្រោះតែបានស្លាប់ទៅជាខ្មោចបានឃ្លាតពីមនុស្សលោកទាំងឡាយហើយពេលនេះខ្ញាឈឺចាប់សារជាថ្មីដោយគ្រាន់តែចង់ចូលមកលេងផ្ទះដែលធ្លាប់រស់នៅ។

ខ្ញាយំ ខ្ញាពេប ខ្ញានឹកដល់គុណអ្នកម្ដាយថ្ងៃ ហើយចង់ឲគាត់បានដឹងពីទុក្ខរបស់ខ្ញាទាំងនេះ។ ខ្ញាពិតជាចង់ឲគាត់មកថ្នាក់ថ្នមខ្ញាដូចអ្វីដែលខ្ញាធ្លាប់បានទទួលកាលពីពេលជាមនុស្ស។ នៅពេលនោះហើយដែលខ្ញាបាននឹកឃើញអ្វីៗទាំងអស់ ដែលលោកអ្នកមានគុណទាំងពីរបានយកចិត្តទុកដាក់មកលើខ្ញានៅគ្រប់ពេលដែលខ្ញាមានជំងឺឬពេលដែលខ្ញាមានរឿងលំបាក។ ខ្ញាពិតជាស្ដាយដែលមិនបាននៅបន្តការសងគុណលោកទាំងពីរជាបន្តទៅទៀត ព្រោះតែខ្ញានៅពេលនេះបានក្លាយទៅជាខ្មោចអាសោចទាំងប្រាណទៅហើយ។

ខ្ញាបានមកដល់ក្នុងផ្ទះ ពេលដែលជូនចាស់បានចាកចេញទៅ។ រូបខ្ញាដែលមានសំលៀកបំពាក់រ៉ូបនិងទទូរក្បាលពណ៌សនោះ បានបណ្ដែតខ្លួនសន្សឹមៗនៅក្នុងផ្ទះដែលមានតែភ្លើងអំពូលដ៏តូចកំពុងបំភ្លឺភាពងងឹតដ៏ធំ។ រូបរាងដ៏ចំលែកនេះវាបានធ្វើឲខ្ញាមានការស្រលាំងកាំងនៅពេលដែល

ខ្ញុំបានដើរកាត់កញ្ចក់។ ហើយនៅពេលដែលខ្ញុំសំលឹងមើលរូបរាងរបស់ខ្ញុំតាមរយៈកញ្ចក់នោះ វាបានធ្វើឲខ្ញុំកាន់តែឈឺផ្សារទៅទៀត។ រូបរបស់ខ្ញុំមានពណ៌សស្លេស លើកលែងតែមុខចេញដែលហើមអស់ហើយប្រមុះមាត់ភ្នែកដោយសារតែការទួញសោក។ ផ្ទៃមុខរបស់ខ្ញុំមានពណ៌ប៉ៃតងដ៏ខ្មៅ កុំថាតែអ្នកដ៏ទៃដែលឃើញខ្ញុំ សូម្បីតែខ្ញុំខ្លួនឯងផ្ទាល់ក៏ខ្លាចដែរ នៅពេលដែលបានឃើញដំបូងនោះ។

វាជាការពិតណាស់ដែលរូបភាពទាំងនេះ ខ្ញុំធ្លាប់តែបានឃើញនៅក្នុងខ្សែរភាពយន្ត តែពេលនេះខ្ញុំទទួលស្គាល់ហើយថាវាជាការពិត ជាការពិតដែលមិនគួរឲជឿ។

ងាកមកមើលតាមកញ្ចក់លើដៃទាំងពីររបស់ខ្ញុំវិញ វាកំពុងតែហូរធ្លាក់ទៅក្រោម នូវដំណៅរលេសរលួយ ដោយសារតែការវាយយកឈ្នះពីដូនតាស់។ឯខាងក្រោមវិញ ខ្ញុំលែងឃើញជើងរបស់ខ្ញុំទៀតហើយ។ ខ្ញុំធ្វើដំណើរទៅមុខទៅក្រោយឬបត់បែនឆ្វេងស្តាំទៅតាមការបណ្តែតខ្លួនទៅតាមខ្យល់។ យប់កាន់តែជ្រៅ ខ្ញុំងើយមើលទៅនាឡិកា វាបានចង្អុលថាម៉ោងពីរហើយ ឯសត្វឆ្កែទាំងឡាយ ហាក់បីដូចជាមិនអស់កំលាំងនិងការស្រែកទាល់តែសោះ។ ខ្ញុំបានបង្ហោះខ្លួនយ៉ាងសន្សឹមៗ សំដៅជាដំបូងចូលទៅក្នុងបន្ទប់សំរាន្តរបស់លោកឪពុកអ្នកម្តាយរបស់ខ្ញុំ។

ខ្ញុំពិតជាអាណិតគាត់ជាពន់ពេក នៅពេលដែលបានឃើញកែវភ្នែករបស់ពួកគាត់ទាំងពីរ បានហើមដោយសារការយំសោកស្តាយរូបកូនរបស់គាត់។ ខ្ញុំបានមកជាប់និងគ្រែ ដោយលើកដៃមកគោរពពួកគាត់ទាំងទឹកភ្នែកហូរធ្លាក់ដោយមិនដឹងខ្លួន។ ខ្ញុំបាននិយាយខ្សឹបៗនៅក្នុងខ្លួនដើម្បីសូមខមាទោសទាំងពួងដែលខ្ញុំបានធ្វើឲពួកគាត់ពិបាក ហើយសូមខមាទោសជាសំខាន់ដែលខ្ញុំមិនបានតបស្នងសងគុណគាត់ឲបានអស់ចិត្តដែលខ្ញុំមាន។ ខ្ញុំមើលពួកគាត់បណ្តើរខ្ញុំស្រក់ទឹកភ្នែកបណ្តើរ។ វានៅតែធ្វើឲខ្ញុំគិតថាមិនសមនិងមានរឿងបែបនេះកើតឡើងទាល់តែសោះ។ខ្ញុំឃើញគាត់គេងស្ងប់យ៉ាងនេះ ខ្ញុំសប្បាយចិត្តណាស់ហើយបានលើកភួយដណ្តប់ទៅឲពួកគាត់ទាំងពីរមុនពេលដែលចេញពីបន្ទប់របស់គាត់។ យប់ស្ងាត់ងងឹតឈឹងនៅ លើផ្លូវដើរខាងក្នុងផ្ទះ វាមានតែពន្លឺពណ៌ដ៏ខៀវខ្ចីចេញពីខ្លួនខ្ញុំតែប៉ុណ្ណោះ ដែលកំពុងតែបណ្តែតខ្លួនទៅកាន់បន្ទប់អ្នកបងស្រីរបស់ខ្ញុំ។





ពេលចូលមកដល់ខាងក្នុងភ្វាម នៅពេលនោះខ្ញុំបានហោះប៉ះទៅនិងធុងទឹកកកមួយលឺសូរ

«ក្រាង!»

ធុងនោះបានដួលទៅម្ខាង ខ្ញុំខំប្រឹងទៅលើកធុងនោះឲមកសភាពដើមមកវិញ ហើយនៅពេលដែលខ្ញុំងើបមុខឡើង ស្រាប់តែខ្ញុំបានឃើញបងស្រីងើបអង្គុយស្ងក់ ដោយភ្ញាក់និងសំលេងធុងដួល។ ខ្ញុំភ្ញាក់ព្រើតដោយបើកភ្នែកធំៗ នៅពេលដែលឃើញគាត់កំពុងសំលឹងមកខ្ញុំ។ ពេលដែលគាត់ដឹងខ្លួនកាលណា គាត់គេងទៅវិញ តែខ្ញុំបានឃើញការយំសោករបស់គាត់ដោយផ្ទាល់។វាពិតជាគួរឲស្រណោះជាទីបំផុត។ នៅពេលនោះខ្ញុំមិនដឹងថាគាត់មើលខ្ញុំឃើញដែរឬទេ? ប៉ុន្តែសំរាប់ខ្ញុំមើលឃើញគាត់ដូចជាធម្មតា។ ខ្ញុំសប្បាយដែរនៅពេលដែលគាត់មិនទាន់គេងដូចនេះព្រោះខ្ញុំមិនចាំបាច់ដាស់គាត់ក៏ខ្ញុំអាចនិយាយជាមួយគាត់បានដែរ។

« អ្នកបង! ខ្ញុំកា មកលេង អ្នកបង!» ខ្ញុំពោល

«ខ្ញុំកាប្អូនប្រុស អ្នកបង អ្នកបងមើលខ្ញុំឃើញទេ?»

«កុំភ័យអ្នកបង ខ្ញុំមិនធ្វើឲគ្រួសារយើងខ្លាចនិងខ្ញុំទេ!»

ទោះបីជាខ្ញុំខំប្រឹងនិយាយយ៉ាងណាក៏ដោយ គាត់ហាក់មិនលឺអ្វីទាំងអស់ គាត់គ្រាន់តែប្រឹងសំលឹងមើលទៅទិដ្ឋភាពនៅជុំវិញបន្ទប់ តែគាត់ក៏ប្រហែលជាមិនដឹងទេថាខ្ញុំកំពុង តែនៅជាប់និងមុខរបស់គាត់។ ខ្ញុំបានបន្តនិយាយទៅគាត់ទៀតថា៖

«អ្នកបងមើលខ្ញុំឃើញទេ?»

«ខ្ញុំកា ខ្ញុំមកលេងអ្នកបង»

គាត់នៅតែមិនលឺហើយនៅតែសំលឹងមើលទិដ្ឋភាពនៅក្នុងបន្ទប់ ខ្ញុំដឹងថាគាត់មានអារម្មណ៍ប្លែកដោយសារតែភាពត្រជាក់របស់ខ្ញុំ។គាត់ឈប់យំបន្តិចហើយបានងើបដើរសំដៅទៅទូដាក់ថ្នាំម្យ៉ាងមកលេប។ ដែលខ្ញុំស្មានថាជាថ្នាំងងុយគេង។ ខ្ញុំមិនធ្វើអ្វីឬក៏និយាយអ្វីទៀតទេ ព្រោះខ្ញុំបានដឹងហើយថាទោះបើខ្ញុំខិតខំប្រឹងនិយាយយ៉ាងណាក៏គាត់មិនលឺដែរ ខ្ញុំបានត្រឹមតែនៅឈរធ្មឹងមួយកន្លែងតែប៉ុណ្ណោះ។ នៅក្រោយពីគាត់លេបថ្នាំរួចបានមួយសន្ទុះ គាត់ក៏បានសំងំគេងលក់ទៅ។ គាត់គេងបែរខ្នងទៅនឹងជញ្ជាំងមិនហ៊ានមើលមកទ្វារបន្ទប់ទេ ដែលខ្ញុំអាចស្មានថាគាត់ពេលនោះក៏មានអារម្មណ៍ថាខ្ញុំនៅជិតនោះដែរ។ ខ្ញុំនៅឈរមួយកន្លែងសំលឹង

មើលពីក្រោយខ្នងរបស់គាត់រហូតដល់ខ្ញុំទទួលអារម្មណ៍មួយថាគាត់ពិតជាគេងលក់ហើយទើបខ្ញុំបណ្តែតខ្លួនបន្តមកកាន់បន្ទប់បងប្រុសរបស់ខ្ញុំម្តងដែលនៅខាងលើបន្ទប់របស់អ្នកបង។

ពេលមកដល់ ខ្ញុំបានឃើញគាត់កំពុងតែគេងស្រមុកយ៉ាងស្រួល ទាំងខ្លួនប្រាណទទេស្អាត។ ឃើញដូចនេះ ខ្ញុំបានលើកភួយថ្មមៗគ្របដណ្តប់ទៅឲគាត់ដើម្បីឲបានកក់ក្តៅបន្តិច។ នៅគ្រាដែលខ្ញុំបានងាកខ្លួន ខ្ញុំបានប្រទះឃើញនូវសារពត៌មាន មួយចំនួននៅលើតុដែលនៅ ក្នុងនោះខ្ញុំបានឃើញរូបថតរបស់ខ្ញុំដែលកំពុងតែតំកល់នៅឯវត្តនិងរូបថតរបស់ឃាតករ។កំហឹងរបស់ខ្ញុំបានពុះកញ្ជ្រោលឡើងវិញនៅពេលដែលខ្ញុំបានឃើញរូបអាមនុស្សទុយ៍សនោះ។ ខ្ញុំបាននិយាយនៅក្នុងចិត្តម្តងហើយម្តងទៀតថា គ្មានថ្ងៃណាមួយដែលខ្ញុំត្រូវបំភ្លេចបាននោះទេ។ ខ្ញុំដាច់ខាតនឹងមិនលើកលែងទោសឲមនុស្សនេះឡើយ។ ខ្ញុំស្គាល់ខ្លួនខ្ញុំយ៉ាង ច្បាស់ថា តាំងតែពីខ្ញុំដឹងក្តីកាលណា ខ្ញុំមិនដែលចេះទៅព្យាបាទអ្នកណាម្នាក់នោះទេ តែពេល នេះ ទោះបាបនរកយ៉ាងណាក៏ដោយ ឈាមដាច់ខាតត្រូវតែសងដោយឈាម។ អ្វីដែលខ្ញុំ ឈឺចាប់ទាំងប៉ុន្មានអាឃាតករនឹងត្រូវឈឺចាប់ជាងខ្ញុំទៅទៀត។ ខ្ញុំពិតជាខឹងណាស់ដែលបាន ឃើញរូបវា នៅក្នុងកាសែតពត៌មាន ហើយចង់ហោះទៅច្របាច់កវាឲស្លាប់ នៅក្នុងពេលនោះតែម្តង តែខ្ញុំមិនអាចធ្វើទៅបានដោយសារតែមិនបានដឹងថាត្រូវទៅតាមផ្លូវណា ហើយខ្ញុំក៏មិនដឹងថាត្រូវធ្វើបែបម៉េចនឹងអាចទៅដល់មន្ទីឃុំឃាំងព្រៃសនោះបាន។ ក្រោយពីបានអានអត្ថបទការសែតមួយចប់រួចមក ខ្ញុំបានចេញពីបន្ទប់បងប្រុសរបស់ខ្ញុំ ហើយ បណ្តែតខ្លួនជាបន្តមកកាន់បន្ទប់ប្អូនប្រុសរបស់ពៅខ្ញុំវិញម្តង។ នៅពេលដែលខ្ញុំបានឃើញ គេកំពុងដេកភ្លាម បានធ្វើឲខ្ញុំអស់សំណើចតែម្នាក់ឯងហើយបាត់ទៅវិញនូវកំហឹងទាំងនោះព្រោះតែបានឃើញនូវការដេករបស់គេប្រចេងប្រចាំងដូចជានៅក្មេងនៅឡើយ។ជើងរបស់គេម្ខាងធ្លាក់ពីលើគ្រែឯជើងម្ខាងទៀតអង្គាញ់។ សំរាប់ដៃរបស់គេវិញក៏ដូចនោះដែរ។ ករបស់គេធ្លាក់ពីលើខ្នើយ។ គេដេក ខ្លួនប្រាណរបស់គេហាក់បីដូចជាកំពុងតែរត់ប្រណាំង។ឯភួយរបស់គេក៏ធ្លាក់មកក្រោមគ្រែទៀត។

ជាការពិតណាស់ចាន់ណារិន គេជាប្អូនពៅតែមួយគត់របស់ខ្ញុំ ខ្ញុំស្រលាញ់គេលើសអ្វីៗទាំងអស់នៅក្នុងលោកនេះ។ខ្ញុំពិតជាសប្បាយចិត្តនៅពេលបានឃើញគេ។

ខ្ញុំបណ្តែតខ្លួនមកជិតគ្រែរបស់គេ ហើយបានលើកដៃលើកជើងឲគេមកសភាពដើមវិញ។





ខ្ញុំបានទាញភួយមកដណ្តប់ឲគេដែរ។ មើលមកតុរៀនរបស់គេ ហ៊ឹម! ពិតជាយ៉ាប់ណាស់។ ពិតជាគ្មានសណ្តាប់ធ្នាប់ទេ។ សៀវភៅរបស់គេរប៉ាត់រប៉ាយ ប៊ិច ព្រមទាំងប្រដាប់ប្រដាររបស់គេវិញនៅពាសពេញតុ។ ខ្ញុំគ្រវីក្បាលដោយញញឹម។ ខ្ញុំបានរៀបចំរបស់របរទាំងនោះឲបាន ត្រឹមត្រូវមុនពេលដែលខ្ញុំចាកចេញពីបន្ទប់របស់គេ។

មកកាន់បន្ទប់របស់ខ្ញុំវិញម្តង អ្វីៗហាក់បីដូចជានៅធម្មតា គ្មានអ្វីដែលប្រែប្រួលទេ ។ ខ្ញុំបានបង្អោះខ្លួនឲមកគេងនៅលើគ្រែដូចពីមុន តែពេលនេះខ្លួនប្រាណរបស់ខ្ញុំមិននៅជាប់និងគ្រែទៀតទេ វាគ្រាន់តែជាផងខ្លួនមួយដែលរឹង និងត្រង់ដូចជាបន្ទាត់នៅហើបពីគ្រែប៉ុណ្ណោះ។ ដូចជាទំលាប់ធម្មតា ខ្ញុំចាប់ផ្តើមសំលឹងមើលរូបថតទាំងឡាយដែលនៅព្យួរជាប់និងជញ្ជាំង ហើយពិសេសនោះខ្ញុំបានយករូបថតគូរដណ្តឹងរបស់ខ្ញុំមកមើល មកថើបសារជាថ្មី។ខ្ញុំងើបចេញពីគ្រែដោយការបង្អោះខ្លួនរបស់ខ្ញុំហើយមកមើលនៅទូរដាក់ឥវ៉ាន់របស់ខ្ញុំវិញម្តង។ខ្ញុំឃើញគ្រឿងប្រើប្រាស់មាសពេជ្រដូចជាចិញ្ចៀនខ្សែរដៃខ្សែរករបស់ខ្ញុំនៅដដែលមិនមានអ្នកណាយកទៅណាមកណាទេ។ អ្វីៗហាក់បីដូចជានៅក្នុងសភាពធម្មតា គ្មាន ការផ្លាស់ប្តូរឡើយ។កំពុងតែសំលឹងទៅមើលទិដ្ឋភាពនៅក្នុងបន្ទប់ស្រាប់តែមានមាន់រងាវជាលើកទីមួយ

«គូកៗៗគូក»

វាជាសំលេងម្យ៉ាងដែលវាធ្វើឲខ្ញុំភ្ញាក់ដឹងខ្លួន និងបានធ្វើឲខ្ញុំហឹងស្លឹកត្រចៀកជាងសំលេងលួរបស់សត្វឆ្កែទៅទៀត។ខ្ញុំខំបណ្តែតខ្លួនចេញមកខាងក្រៅវិញដោយកាត់តាមបន្ទប់សុទ្ធាដែលជាអ្នកធ្វើការងារនៅក្នុងផ្ទះ។ ខ្ញុំបានអើតពីខាងក្រៅមើលទៅនាងដែលកំពុងតែងើបពីគេងនិងរៀបចំបត់ភួយមុង។ ខ្ញុំពេញចិត្តនិងនាងណាស់ព្រោះតែនាងឧស្សាហ៍និងការងារផ្ទះ។ ខ្ញុំសំលឹងមើលទៅនាង ហើយនៅពេលដំណាលគ្នានោះស្រាប់តែមានសំលេងខ្យល់បក់មួយយ៉ាងធំលឺសូរប្រាវៗ សុទ្ធាបានសំលឹងមករកប្រភពសំលេងនោះ មានន័យថានាងបានងាកចំមកមើលមុខដ៏ខៀវស្រងាត់របស់ខ្ញុំដោយកែវភ្នែកទាំងពីរនាក់យើងបានសំលឹងដាក់គ្នា។ ពេលខ្ញុំឃើញនាងលើកនេះ វាខុសគ្នាដែលខ្ញុំបានឃើញបងស្រីរបស់ខ្ញុំ ព្រោះយើងមិនបានបាញ់ភ្នែកដាក់គ្នាដូចនេះទេ។ ទោះយ៉ាងណាក៏ដោយខ្ញុំមិនបានដឹងថានាងបានឃើញខ្ញុំដែរឬទេ។ សំរាប់ខ្ញុំក៏ភ័យណាស់ដែរ។

«គ្លុកៗៗគ្លុក» ជាសំលេងទីពីរទៅហើយ ខ្ញុំមិនអាចនៅបន្តលេងទៀតបានទេ ខ្ញុំបានប្រឹងហោះសំដៅមកខាងក្រៅដោយពេលនោះបានសំលឹងមើលទៅនាឡិកាបានបញ្ជាក់ថា វាម៉ោង៥ភ្លឺទៅហើយ។ ខ្ញុំហោះបណ្តើរខ្ញុំលើកដៃសំពះលាលោកអ្នកមានគុណបណ្តើរ ថាខ្ញុំលាសិនហើយលាទាំងអាល័យ លាទាំងសោកស្តាយ លាទាំងមិនអស់ចិត្តទាល់តែសោះ ហើយនឹកនៅក្នុងចិត្តថាបើមានឱកាសនឹងមកលេងពួកគាត់ម្តងទៀតមិនខាន។ ប៉ុន្មានវិនាទីប៉ុណ្ណោះខ្ញុំបានមកដល់កន្លែងដើមដែលនៅទីនោះខ្ញុំបានរំលឹកដល់ឈ្មោះ «បុទមវត្តី» ស្រាប់តែពេលនោះរូបរបស់ខ្ញុំបានរលាយចេញពីគេហដ្ឋានដ៏កំសត់របស់ខ្ញុំទៅ គេហដ្ឋានដែលខ្ញុំបានរស់នៅអស់រយៈពេលជាង៣០ឆ្នាំមកហើយ។ ឃ្លាតពីលោកអ្នកមានគុណទាំងពីរ បងប្រុសបងស្រីព្រមទាំងប្អូនសំលាញ់ចិត្ត។ ខ្ញុំស្រក់ទឹកភ្នែកនឹកស្រណោះខ្លួន រកពាក្យមកប្រាប់ចាន់ណារិនឯង មិនបានទេមុនពេលដែលខ្ញុំរលាយចេញពីទីនោះ។

បន្តិចតែប៉ុណ្ណោះខ្ញុំបានមកដល់វិញឯភពថ្មី ភពដែលខ្ញុំធ្លាប់បានមក។ នៅទីនោះគ្មានអ្វីខុសប្លែកពីមុននោះទេ ក្រៅអំពីមានផ្ទៃពណ៌សក្បុសនៅជុំវិញខ្លួនប្រាណរបស់ខ្ញុំ។ នៅខាងមុខពីចំងាយ ខ្ញុំបានឃើញបុទមនិងវត្តីកំពុងហោះសំដៅមករកខ្ញុំ ពេលដែលមក ដល់ជិតវត្តីបានបន្លឺឡើងថា៖

«ម៉េចហើយបង បានធូស្បើយពីអារម្មណ៍ខ្លះទេ?»

ខ្ញុំមិននិយាយអ្វីទាំងអស់ក្រៅពីញញឹមតិចៗដាក់ទៅពួកនាងវិញ

«តោះបង ពួកយើងត្រូវដល់វេលាទៅជួបស្តេចយមរាជហើយ» បុទមបន្ត

ខ្ញុំមិននិយាយអ្វីទាំងអស់ក្រៅពីងក់ក្បាលយល់ព្រម។ ពួកនាងទាំងពីរបានលាបាតដៃក្នុងបំណងឲខ្ញុំប្រគល់ដៃទៅឲនាង ខ្ញុំក៏បានធ្វើតាមហើយពួកយើងទាំងបីនាក់បានចេញដំណើរពីទីនោះមកកាន់ឋាននរក។ ពួកខ្ញុំទាំងបីនាក់បានហោះនៅក្នុងល្បឿនយ៉ាងលឿនចុះទៅខាងក្រោមដែលឆ្លងកាត់ពីពន្លឺពណ៌សទៅកាន់ពន្លឺពណ៌ខ្មៅស្លុប។ ខ្ញុំក៏មានការភ័យខ្លាចណាស់ដែរតែខ្ញុំបានខំប្រឹងទប់ស្មារតីដោយកាន់ដៃពួកនាងយ៉ាងណែន និងខិតខំបំភ្លេចនូវអ្វីដែលកំពុងតែកើតឡើងនិងការឈឺចាប់ទាំងឡាយ។ ខ្ញុំមិនហ៊ានបើកភ្នែកទេនៅពេលធ្វើដំណើររហូតដល់តែខ្ញុំបានបញ្ឈប់ការហោះហើរនៅលើឋានមួយ។ បុទមវត្តីបានក្រលេកមកមើលខ្ញុំដែលកំពុងតែ





បើកភ្នែកសន្សឹមៗមកមើលឋានថ្មីនេះ។ កាលណាដែលខ្ញុំបានបើកភ្នែកពេញលេញហើយខ្ញុំបានដឹងថាខ្ញុំបានមកដល់ក្លោងទ្វារមួយដ៏ធំដែលនៅជាប់នោះមានអ្នកយាមពីរនាក់ឈរនៅជាប់បង្គោលភ្លើង ដែលមានពណ៌ក្រហមឆ្អៅ។ ពួកយើងទាំងបីបានហោះបន្តទៅកាន់ក្លោងទ្វារនោះ។ បុទមបានលាបាតដៃខាងស្តាំបង្ហាញទៅពួកអ្នកយាម។ កាលបើបានទទួល សញ្ញានេះហើយ អ្នកយាមងក់ក្បាលគោរពពួកយើងទាំងបី ហើយនិងបានបើកទ្វារឲពួកយើងអាចចូលបានទៅខាងក្នុង។

ចាន់ណារិនអើយ! នៅពេលនោះខ្ញុំរិតតែមានការភ័យខ្លាចរកពាក្យណាមករៀបរាប់ពុំបានឡើយ។ វាជាភពមួយ ភពដែលខ្ញុំមិនដែលស្រមៃថានឹងបានមកដល់នៅពេលនេះទេ។ ខ្ញុំខ្លាចណាស់តែខ្ញុំនៅតែប្រាប់អារម្មណ៍ខ្លួនខ្ញុំថា គ្មាននរណាម្នាក់នឹងអាចជៀសផុតពីទិដ្ឋភាពទាំងនេះឡើយ។ ខ្ញុំហោះកាន់ដៃអ្នកទាំងពីរបណ្តើរខំក្រលេកមើលទិដ្ឋភាពទាំងឡាយនៅជុំវិញខ្លួនរបស់ខ្ញុំបណ្តើរ។ ខ្ញុំឃើញតែផ្សែងតែប៉ុណ្ណោះដែលលាយឡំទៅនិងភ្លើងពណ៌ក្រហមខ្ទៅ។ ពួកយើងទាំងបីបានហោះកាត់ផ្សែងពណ៌ទាំងនោះរហូតមកដល់វិមានមួយដែលមានក្លោងទ្វារមួយទៀតដែលល្អប្រណិតហើយនៅពីមុខនោះ មានបុរសចំណាស់ម្នាក់នៅកំពុងតែឈររងចាំពួកយើង។

«សូមគោរពលោកប្រុសគៀនកា» គាត់ពោល

ខ្ញុំបានអោនក្បាលគោរពទៅគាត់វិញដោយមិនដឹងរកពាក្យឯណាមកនិយាយគ្មាន ព្រោះវារំភើបពេកនៅពេលដែលគាត់បានស្គាល់ឈ្មោះខ្ញុំច្បាស់បែបនេះ។

«ព្រះរាជាកំពុងតែរងចាំលោកប្រុស» គាត់បន្ថែម

ខ្ញុំញញឹមទទួលដោយសេចក្តីគោរព ហើយពួកយើងទាំងបីនាក់បានហោះតាមលោកតាចំណាស់នោះដោយសន្សឹមៗ។

មកដល់កន្លែងកំណត់ ពួកយើងទាំងបួនបានឈប់ព្រមគ្នា ហើយបុរសចំណាស់នោះបានអោនគោរពទៅបុរសចំណាស់ម្នាក់ទៀតដែលខ្ញុំគិតថាជាមនុស្សដែលមានឋានៈបុណ្យស័ក្តិធំធុំ។ លោកតាចំណាស់ទីមួយបាននិយាយខ្លាំងថា៖

«សូមក្រាបថ្វាយបង្គំព្រះរាជា លោកប្រុសគៀនកាបានមកដល់ហើយ»

កាលបើបានលឺពាក្យថាព្រះរាជានោះ បានធ្វើឱគ្នានៅតាំងមួយកន្លែងហើយនិងមិនអាចរកពាក្យអ្វីមកនិយាយចេញនោះទេ បន្តិចមកគ្នាបានលឺសំលេងចេញពីខាងមុខគ្នាថា៖

**«សូមរកកន្លែងគួរសមចុះ!»**

មន្ត្រីចំណាស់កាលបើបានលឺពាក្យនេះហើយ គាត់បានធ្វើសញ្ញាមកឱពួកយើងឱរំកិលខ្លួនដោយអោនលំទោនមកកាន់កូនតុមួយដែលនៅក្បែរនោះ។ គ្នាមានកៅអីអង្គុយដោយសល់តែបុទមវត្តីដែលត្រូវឈរអមសងខាងគ្នា។

ឯបុរសចំណាស់នោះវិញ បានឡើងទៅឈរនៅខាងលើខាងស្តាំដៃនៃព្រះរាជា ដែលកំពុងតែប្រថាប់នៅឯតុដ៏ធំជាងគេនៅក្នុងបន្ទប់។

បុរសម្នាក់ដែលគ្នាបានដឹងថាជាព្រះរាជានោះ មានមុខមាត់មិនដូចជាគ្នាយើងនោះទេ ។ ថ្វីស្បិតតែព្រះអង្គជាស្តេចដែលគ្រប់គ្រងទៅដោយពពួកខ្មោច ពពួកនរកប្រែតគួរឱខ្លាចក៏ដោយ ប៉ុន្តែព្រះអង្គគឺជាអង្គក្សត្រមួយអង្គដែលមានព្រះភ័ក្រគួរឱចង់គយគន់ ព្រះភ័ក្រដែលពោរពេញទៅដោយមេត្តាករុណាដល់ពពួកខ្មោចទាំងឡាយ ដែលវង្វេងទៅដោយមាសប្រាក់បុណ្យស័ក្តនៅឯឋានមនុស្សលោក។ ទឹកព្រះភ័ក្ររបស់ព្រះអង្គពិតជាស្រស់ស្អាតណាស់ដែលគ្នាមើលទៅហាក់ទើបតែមានព្រះជន្មទើបបាន៣០ព្រះវស្សាប៉ុណ្ណោះ។ ព្រះអង្គដកដង្ហើមមួយៗ សំលឹងមករកពួកយើងដោយសេចក្តីស្វាគមន៍។ ចំណែកឯរូបរាងនោះសោត ព្រះអង្គពិតជាមិនចាញ់តារាភាពយន្តហូលីវូតប៉ុន្មាននោះទេ។ព្រះអង្គមានសំលៀកបំពាក់ដូចជាមេទ័ពនៅក្នុងសម័យអង្គរ។ ឯកសណ្ឋានរបស់ព្រះអង្គបើតាមតែគ្នាមើលពីចំងាយ ហាក់បីដូចជាធ្វើអំពីមាស។ ព្រះអង្គមានពាក់ម្កុដនៅលើព្រះកេសដែលនៅលើនោះមានគ្រាប់ពេជ្រមួយយ៉ាងធំ ភ្លឺចិញ្ចាញពេញផ្ទៃបន្ទប់។ នៅលើតុរបស់ព្រះអង្គវិញមានរបស់របរជាច្រើន តែអ្វីដែលគ្នាឃើញនិងស្គាល់មុនគេនោះគឺគ្រារបស់ព្រះអង្គនិងគ្រឿងសុរា។ ព្រះអង្គនៅគង់ដោយអមសងខាងដោយស្ត្រីក្មេងពីរនាក់ទៀត ដែលគ្នាស្មានប្រហែលជាអគ្គមហេសីរបស់ព្រះអង្គ ឬក៏ប្រហែលជាស្នំរបស់ព្រះអង្គ។ នៅពេលដែលគ្នាមើលទៅព្រះអង្គ គ្នានៅរក្សាស្នាមញញឹមជាប់ជានិច្ច នោះដើម្បីឆ្លើយតបទៅហ្នឹងព្រះភ័ក្រដ៏ស្រទន់របស់ព្រះអង្គវិញ។ នៅពេលនោះគ្នាមិនអាចនិយាយអ្វីជាមួយនិងបុទមវត្តីបានទេ ព្រោះនាងនៅឈរខាងក្រោយខ្នងរបស់គ្នា ហើយគ្នាក៏មិនចង់ងាក





ចុះឡើងអីដែរ។

ក្រលេកមកមើលនៅខាងក្រោមតុរបស់ព្រះអង្គវិញ មានមនុស្សប្រមាណជា១០នាក់ដែលនៅក្នុងនោះក៏មានគ្នាដែរ។ ពួកយើងទាំងអស់គ្នាបានអង្គុយនៅលើតុម្នាក់មួយៗរៀងៗខ្លួន ហើយម្នាក់ៗក៏មានសំលៀកបំពាក់ពណ៌សដូចជារូបគ្នាដែរ។ នៅលើតុរបស់ពួកយើងនេះវិញក៏មានគ្រឿងសុរានិងអាហារផ្សេងៗទៀតដែរ។ក្នុងពិធីចូលគាល់ព្រះអង្គនៅពេលនោះ គ្នាពិតជាមើលស្ទើតែមិនឃើញទៅហើយ ព្រោះតែបន្ទប់មានពន្លឺតិចពេក។ គ្នាបានគិតផងដែរថាម្នាក់ៗដែលមានវត្តមាននៅទីនោះជាមួយគ្នាប្រាកដ ណាស់ដែលពួកគេមានអារម្មណ៍មិនខុសពីគ្នាប៉ុន្មាននោះទេ។ ពួកគេក៏ប្រហែលជាទើបនិងស្លាប់ដូចជាគ្នាដែរ តែគ្រាន់តែការស្លាប់មានលក្ខណៈខុសគ្នាប៉ុណ្ណោះ។ក្នុងចំណោម១០នាក់រួមទាំងគ្នាផងនោះ ពួកយើងហាក់បីដូចជាមានអាយុប្រហាក់ប្រហែលគ្នា។ គ្នាកំពុងតែរំពៃមើលមុខពួកគេ ស្រាប់តែព្រះរាជាបានមានបន្ទូលក្នុងពេលដំណាលគ្នានោះឡើងថា៖

**«យើងសូមស្វាគមន៍ពួកអ្នកទាំងអស់គ្នាដែលបានមកដល់ទីនេះ»**

ព្រះអង្គឈប់បន្តិចហើយបន្តទៅទៀតថា៖

**«តាមអ្វីដែលលោកឧបរាជប្រាប់មកយើង យើងបានដឹងនិងស្គាល់ពីជីវប្រវត្តិរបស់ពួកអ្នកទាំងអស់គ្នាយ៉ាងច្បាស់ ហើយក៏ដឹងផងដែរថាពួកអ្នកជាមនុស្សមានបុណ្យ មនុស្សល្អតែបែរជាត្រូវស្លាប់ដោយអំពើអយុត្តិធម៌ទៅវិញ។ យើងសូមប្រាប់ថា ពួកអ្នកដែលបាន មកជួបយើងនៅទីនេះគឺសុទ្ធតែជាអ្នកមានវាសនាល្អទាំងអស់បើមិនដូចនេះទេពួកអ្នកអ្វី......»**

ព្រះអង្គធ្វើរៀចកនិងមាត់បន្តិចហើយបន្តទៀតថា៖

**«ប្រហែលជាត្រូវគេខ្វៃមិនខាន មែនទេលោកឧបរាជ?»**

ព្រះអង្គក្រលេកទៅមើលលោកឧបរាជដែលនៅជិតនោះ ឯលោកឧបរាជបានងក់ក្បាលទទួលស្គាល់ថាពាក្យសំដីរបស់ព្រះអង្គគឺពិតជាត្រឹមត្រូវ។

គ្រាន់តែលឺពាក្យនេះភ្លាម ម្នាក់ៗរួមទាំងគ្នាបានផ្ទុះសំណើចតិលលាន់សូរឱរណ្តំពេញផ្ទៃបន្ទប់ ហើយព្រះអង្គខ្លួនឯងក៏ដូចជាលោកឧបរាជនាំគ្នាសើចព្រមគ្នាដែរ។ ម្នាក់ៗរួមទាំងគ្នាទៀតនោះហាក់បី ដូចជាបានភ្លេចខ្លួនថាបានស្លាប់ទៅហើយ ហើយបែរជានាំគ្នាសប្បាយទៅវិញ។ ព្រះអង្គ

បានបន្តទៅទៀតដោយស្នាមញញឹមពព្រាយថា៖

«អ្វីដែលយើងចង់ប្រាប់ពួកអ្នកទាំងអស់គ្នានៅពេលនេះ គឺសូមកុំឱមានការសោកស្តាយអ្វីទាំងអស់អំពីជីវិតជាតិមុន ព្រោះវាគ្រាន់តែជាសុបិន្តមួយតែប៉ុណ្ណោះ ហើយគ្រប់គ្នាត្រូវតែបញ្ចប់សុបិន្តនោះគ្រាន់តែមុនហើយនិងក្រោយតែប៉ុណ្ណោះ»

ចប់ឃ្លាបានប៉ុណ្ណេះ ព្រះអង្គបានងាកទៅមើលលោកឧបរាជហើយពោលបន្តទៅទៀតថា៖

«លោកឧបរាជតើកម្មវិធីអ្វីខ្លះដែលពួកគេត្រូវធ្វើបន្ត?»

លោកឧបរាជអោនក្បាលគោរពព្រះអង្គ រួចហើយដើរចេញមកមុខបន្តិចទាំងលើកតារាងមួយយកមកអានប្រកាសប្រាប់ពួកយើងទាំង១០នាក់ថា៖

«ដោយពួកអ្នកទាំងអស់គ្នាបានសាងតែអំពើល្អមិនប្រព្រឹត្តអំពើបាបកាលពីនៅរស់ និងនៅក្រោមបុណ្យបារមីនិងការប្រោសប្រទានរបស់ព្រះរាជានាឋាននរក យើងសូមប្រកាសកម្មវិធីរបស់ពួកអ្នកដូចតទៅ៖

១. ពួកអ្នកនឹងត្រូវប្រទានដោយព្រះអង្គនូវអាហារទេពមួយពេលនេះ

២. ពួកអ្នកទាំងអស់គ្នាត្រូវអនុញ្ញាតឱចុះទៅទស្សនាពពួកប្រែតដែលកំពុងរស់នៅក្នុងឋាននរកទាំង១០ជាន់

៣. ពួកអ្នកនឹងត្រូវបានដោះលែងឱទៅកាន់ទីផ្សរ ឈាបនដ្ឋានដែលបានបញ្ចុះឬក៏បូជាពួកអ្នក ដែលនៅទីនោះពួកអ្នកអាចដើរទៅណាមកណាមួយសេរី នៅពេលដែលគ្មានពន្លឺព្រះអាទិត្យ។ តែនៅពេលថ្ងៃ ពួកអ្នកត្រូវរៀនទន្និញគម្ពីរធម៌ដែលខ្ញុំនឹងចែកពួកអ្នកនៅពេលបន្តិចទៀតនេះ។ គម្ពីធម៌ទាំងនេះ ពួកអ្នកត្រូវតែទន្និញឱបានចាំស្ទាត់ ហើយព្យាយាមបំភ្លេចនិងបោះបង់ចោលឱអស់នូវរាល់កាមកិលេសទាំងឡាយ ដែលពួកអ្នកធ្លាប់មានកាលពីនៅជាតិជាមនុស្ស។ សូមបញ្ជាក់ថា អ្នកទន្និញកាន់តែចាំស្ទាត់ អ្នកនោះកាន់តែមានបុណ្យបារមីហើយកាន់តែមានសិទ្ធិក្នុងការរើសភពថ្មីទៅតាមដែលចិត្ត របស់គេប្រាថ្នា។

៤. គំរប់បានមួយរយថ្ងៃនៃការស្លាប់ ពួកអ្នកទាំងអស់គ្នាត្រូវត្រលប់មកទីនេះវិញជាកំនត់ ដើម្បីវិនិច្ឆ័យការប្រឹងប្រែងរបស់ពួកអ្នក នៅពេលទន្និញធម៌ ហើយជារួលដែលពួកអ្នកត្រូវសំរេចចិត្តថាតើពួកអ្នកចង់ទៅកើតនៅឋានណា ភពណានៅក្នុង ចំណោម





ឋានទាំងបី។តើពួកអ្នកមានសំនួរអ្វីទេ?»

លោកឧបរាជបានសួរមកពួកយើងដែលគ្រប់គ្នាបានមើលមុខគ្នាឡេងឡង់ៗ ហើយនៅពេលនោះមានបុរសម្នាក់បានលើកដៃ ដើបឈរហើយសួរទៅលោកឧបរាជថា៖

«នៅពេលមានពន្លឺព្រះអាទិត្យខ្ញុំត្រូវចូលពួនសំងំលាក់ខ្លួនខំប្រឹងទន្និញធម៌ចុះបើពេលយប់វិញតើខ្ញុំអាចទៅលេងបងប្អូនក្រុមគ្រួសារមិត្តភក្តិបានដែរឬទេ?»

«ពួកអ្នកមានសិទ្ធចង់ទៅណា ធ្វើអ្វីក៏បានដែរ តែប្រសិនបើពួកអ្នកយកមហិទ្ធិរិទ្ធទាំងនោះទៅរំខានគេនៅក្នុងបំណងអាក្រក់ឬក៏សំលាប់គេវិញដើម្បីសងសឹកនូវអ្វីដែលមនុស្សលោកបានធ្វើមកលើពួកអ្នកនោះ ពួកអ្នកនឹងត្រូវធ្លាក់នរកនៅជាន់ទី១០ហើយនឹងត្រូវរងទុក្ខវេទនារាប់លានឆ្នាំមិនខាន។ បន្តិចទៀតនេះពួកអ្នកនឹងបានឃើញមិនខាននូវការធ្វើទារុណកម្មយ៉ាងម៉េចនៅឋាននរករបស់ពួកយើង» លោកឧបរាជបានឆ្លើយមកកាន់បុរសនោះ

«បើល្អមិនចង់ឱមានបាបកម្មតទៅទៀតពួកអ្នកគួរតែទន្និញធម៌ទាំងយប់ទាំងថ្ងៃទៅហេ...ហេ...នោះប្រសើរមិនខាន!» ព្រះអង្គមានបន្ទូលបណ្តើរសើចឱកក្អឹកបណ្តើរ។

ចំណែកឯពួកយើងវិញនាំគ្នាផ្ទុះសំណើចទៅតាមព្រះអង្គដែរ។ នៅពេលដំណាលគ្នានោះ ស្រាប់តែមានយុវតីម្នាក់បានងើបឈរហើយនិយាយទាំងមាំថា៖

«សូមគោរពលោកឧបរាជ សូមថ្វាយបង្គំព្រះរាជា ដូចជារូបទូលបង្គំដែលត្រូវគេរំលោភផ្លូវភេទដោយកំរោលហើយមិនត្រឹមតែប៉ុណ្ណោះ គេបានសំលាប់ដោយចាក់បំពង់ករបស់ខ្ញុំព្រះករុណាទៀត តើខ្ញុំព្រះករុណាគួរតែអត់អោនឱមនុស្សនោះបានសុខមែនទេ?»

ពួកយើងទាំងអស់គ្នាបានស្តាប់នាងទាំងយកចិត្តទុកដាក់ ឯលោកឧបរាជវិញបានបានឆ្លើយតបទៅនាងវិញថា៖

«តាមច្បាប់របស់ធម្មជាតិ អ្វីដែលគេបានធ្វើមកលើរូបនាងនៅជាតិនេះ គឺជាកម្មដែលនាងបានប្រព្រឹត្តកាលពីជាតិមុន ដូចនេះហើយបានជាជាតិនេះគេត្រូវមកជំរះកម្មជាមួយនាងវិញ ហើយបើនាងនៅចង់បន្តការសងសឹកទៀតនោះ គំនុំនិងមិនមានការបញ្ឈប់ឡើយ វានឹងបន្តជារៀងរហូត។ដូចជាខ្ញុំបានប្រាប់ពួកអ្នកអំបាញ់មិញហើយ បើសិនជាពួកអ្នកហ៊ានប៉ះពាល់ពួកមនុស្សទាំងនោះដោយមហិទ្ធិរិទ្ធរបស់ខ្លួន ពួកអ្នកនឹងទទួលរងទុក្ខវេទនាជាទីបំផុតនៅក្នុងឋាននរក

ដែលពួកអ្នកនឹងឃើញនៅពេលបន្តិចទៀតនេះ។ ពួកអ្នកត្រូវចាំថា នៅថ្ងៃដំបូងនៃការទន្និញធម៌ ពួកអ្នកនឹងអាច ស្រម៉ៃថាហេតុអ្វីបានជាជាតិនេះអ្នកមានកម្មត្រូវស្លាប់យ៉ាងដូចនេះ? តើអ្នកធ្លាប់មានរឿងអ្វីខ្លះជាមួយឃាតករ បានជាជាតិនេះគេតាមមកយកជីវិតរបស់អ្នកវិញនោះ។ ខ្ញុំសូមអង្វរពួកអ្នកគួរតែទុករឿងសងសឹកទាំងនេះ ទៅឲឋាននិមួយៗដោះស្រាយទៅ យើងនៅទីនេះយើងមានច្បាប់របស់យើង ឯគេនៅខាងលើក៏គេមានច្បាប់របស់គេដែរ។ មិនចាំបាច់ពួកអ្នកទៅសងសឹកនោះទេ ពួកដែលបានសំលាប់ពួកអ្នកនោះនឹងរស់នៅទាំងវេទនា ក្នុងជាតិជាមនុស្ស ហើយនៅពេលដែលគេស្លាប់មកទីនេះ គេក៏នឹងត្រូវទទួលទុក្ខទោសរាប់រយលានឆ្នាំទៅទៀត។

ពួកអ្នកគួរតែបញ្ឈប់ការសងសឹកគ្នាទៅវិញទៅមកទៅ! នោះប្រសិនបើពួកអ្នក មិនចង់ឲមានកម្មវេរាទៅអនាគតជាតិខាងមុខ។ ពួកអ្នកដែលមានវត្តមាននៅទីនេះ សុទ្ធតែជាអ្នកមានបុណ្យទៅហើយ សូមកុំឲបុណ្យផលរបស់ពួកអ្នករលាយទៅវិញដោយសារតែកំហឹង កំហឹងនៃការសងសឹកដោយគ្មានប្រយោជន៍នោះវាពិតជាគួរឲស្តាយណាស់។ ការសាងបុណ្យមិនងាយនោះទេ តែបើការសាងបាបវិញប្រាកដណាស់ថាវាងាយស្រួល។

ខ្ញុំសូមប្រាប់ពួកអ្នកទាំងអស់គ្នាថាតាមទូរលេខនៅក្នុងឋានមនុស្សលោកឥឡូវនេះ មានមនុស្សប្រមាណជា៨០ភាគរយទៅហើយដែលពួកគេទាំងនោះបានស្គាល់បុណ្យនិងបាប ហើយឥឡូវនេះ គេកំពុងតែបន្តការធ្វើបុណ្យដាក់ទានគឺសំរាប់អនាគតជាតិរបស់គេ នៅពេលដែលគេត្រូវអស់កម្មវេរានៅឯឋានមនុស្សលោកនោះ។»

«ពួកអ្នកទាំងអស់គ្នាគួរតែស្តាប់ដំបូន្មានរបស់លោកឧបរាជ» ព្រះអង្គបន្ត

លោកឧបរាជបានប្រកាសបន្តទៅទៀតក្រែងនៅមានសំនួរបន្ត។ លោកក៏បានបន្ថែមប្រាប់យើងផងដែរដល់ថ្ងៃកំណត់ បើកាលណាយើងមិនមកទទួលការវិនិច្ឆ័យនោះទេ ដួងប្រលឹងរបស់ពួកយើងនឹងមិនអាចចូលមកទីនេះបានទៀតទេ។នៅពេលបន្ទាប់ក៏មានបុរសម្នាក់ទៀតបានងើបសួរថា៖

«នៅពេលដែលពួកយើងបានទន្និញបានចាំស្ទាត់ហើយតើពួកយើងអាចទៅធ្វើអ្វីបានខ្លះ?»

«ស្រេចតែពួកអ្នកទេ ពួកអ្នកអាចទៅបន្តការងារនៅឋានលើឋាននេះ ឬក៏ត្រលប់ទៅកាន់ឋាន





កណ្តាលវិញ អ្វីៗនឹងត្រូវបង្ហាញនៅលើតារាងលទ្ធផលរបស់ពួកអ្នក ក្រោយពីបានតាំងសមាធិរួច»

ចប់សំដីត្រឹមនេះ ព្រះរាជាបានក្រលេកមើលស្នំទាំងពីរហើយមានបន្ទូលឡើងថា៖

«យើងត្រូវការអ្នកការពារពីរនាក់ទៀតនៅឋាននេះ បើមានអ្នកណាចង់ យើងនឹងព្រមទទួលឲមកការពារស្នំទាំងពីររបស់យើង!»

ឃើញព្រះអង្គមានបន្ទូលបែបនេះ លោកឧបរាជបានខ្សឹបដាក់ព្រះអង្គហើយត្រូវបានព្រះអង្គខ្ញាល់ដោយស្រែកខ្លាំងៗមកវិញថា៖

«យ៉ីសមិនបានទេ! ឥឡូវនេះផ្អើលសំបើមណាស់អំពីការចាប់រំលោភស្ត្រីហើយសំលាប់ យើងក៏បារម្ភពីសុវត្ថិភាពរបស់ពួកនាងទាំងពីរដែរ!»

ពួកយើងនៅឯខាងក្រោមឯនេះវិញនាំគ្នាមើលមុខគ្នាទៅវិញទៅមកដោយញញឹមមិនហ៊ានផ្ទុះសំណើចនោះទេ។

ការបរិភោគបានចាប់ផ្តើមឡើង ព្រះអង្គបានលើកកែវស្រាពីចំងាយដើម្បីទទួលស្វាគមន៍ ពួកយើងក្នុងពេលដំណាលគ្នានោះក៏លើកជូនព្រះអង្គវិញដែរ។

ណារិនអើយ! នៅពេលដែលគ្នាបានផឹកស្រានោះគ្នាមិនដឹងថា វាមានរសជាតិអ្វីទាំងអស់ តែគ្នាចេះតែលេបទៅ។ មើលមកម្ហូបវិញមានបីចាន ចានទីមួយមានស្លឹកពណ៌ខៀវដែលគេថាញ៉ាំហើយសំរាប់បំបាត់ការភ័យខ្លាច។ ចានទីពីរពណ៌ក្រហម សំរាប់បំបាត់ការឈឺចាប់និងបំភ្លេចនូវរឿងអតីតទាំងប៉ុន្មាន ឯចានទីបីវិញមានពណ៌ស ដែលជានិមិត្តរូបសំរាប់ភាពសប្បាយរីករាយតទៅ។ ពួកគ្នាទាំងដប់នាក់បាននាំគ្នាញ៉ាំស្លឹកទាំងនោះទាល់តែអស់ពីចាន។ ពួកយើងនាំគ្នាញ៉ាំនៅពេលជាមួយគ្នានិងព្រះរាជា។ ពេលដែលគ្នាងាករកបុទមវត្តីក្រែងនាងចង់ញ៉ាំដែរ តែពួកនាងគ្រវីក្បាលហើយបើកភ្នែកជាសញ្ញាឲគ្នាប្រឹងញ៉ាំឲអស់។ គ្នាមិនដឹងថា ជាតិអ្វីទេស្លឹកទាំងនោះ។ គ្នាចេះតែទំពារទៅ ម្នាក់ៗក៏មិនខុសពីគ្នាប៉ុន្មានដែរ ធ្វើមុខជូរព្រោះតែ មិនធ្លាប់បានបរិភោគពីមុនមក។ លើកលែងតែព្រះរាជាតែប៉ុណ្ណោះដែលសោយទំនងជាឆ្ងាញ់ណាស់។

ពួកយើងទាំងអស់គ្នាបានបរិភោគយ៉ាងស្ងាត់ស្ងៀមមិនហ៊ានមាត់កអ្វីទាំងអស់។

ក្រោយពីសោយរួចរាល់ហើយព្រះអង្គបានប្រកាសឲសេនាម្នាក់ចូលមកគាល់ព្រះអង្គ។ម្នាក់នោះ

បានចូលមកតាមការកោះហៅហើយបានថ្វាយបង្គំព្រះអង្គយ៉ាងសមរម្យ។

ព្រះរាជាបានមានព្រះបន្ទូលឡើងថា៖

**«មើលលោកសេនាឯកសូមជួយនាំពួកគេទាំងនេះទៅលេងឋាននរកទាំង១០របស់យើងផង»**

**«ព្រះករុណាថ្លៃវិសេស»** សេនាបានឆ្លើយ

សេនានោះមានមាឌធំ ខ្ពស់ មានសំបុរខ្មៅក្រិប។ ដៃជើងធំៗហើយមានសំលៀកបំពាក់ដូចជាមេទ័ពដែរ។ កាលនោះគេបានឈរនៅពីមុខគ្នាតែគ្នាមិនបានចាប់អារម្មណ៍ជានរណានោះទេ។

នៅមុនពេលដែលព្រះរាជាបានចេញទៅ ព្រះអង្គបានជូនពរពួកយើងឲបានសំរេចក្នុងការតាំងសមាធិទាំងនោះ ហើយព្រះអង្គមានសេចក្តីសង្ឃឹមថានឹងបានជួបពួកយើងម្តងទៀតនាឱកាសដែលពួកយើងបានត្រលប់មកវិញជាមួយនិងលទ្ធផលដ៏ល្អប្រសើរនោះ។

ក្រោយពីការផ្តែផ្តាំទៅសេនារបស់ព្រះអង្គរួចហើយ ទាំងព្រះអង្គនិងលោកឧបរាជបានចាកចេញទៅ ឯលោកសេនាដែលមាននាទីជូនពួកយើងទៅកំសាន្តនៅឋាននរកបានងាកមករកពួកយើងហើយបាននិយាយឡើងថា៖

**«សូមពួកអ្នកទាំងអស់គ្នាមកតាមខ្ញុំ ខ្ញុំនិងជូនឲបានស្គាល់ឋានរបស់ពួកខ្ញុំ»**

ក្រោយពីបានលឺសំលេងនេះភ្លាម គ្នាហាក់បានចាំម្ចាស់សំលេងហើយគ្នាបានស្រែកសួរឡើងថា៖

**«ស៊ីណាត........... ស៊ីណាត............ ខ្ញុំណាំ កា...!»**

ស៊ីណាតនៅស្ងៀមស្រឡាំងកាំងមួយភាំងទើបគេស្ទុះមកអោបគ្នាហើយនិយាយតបថា៖

**«អ្ហា!.....កាទេអី.....អូយឯងសប្បាយចិត្តណាស់ដែលបានជួបកាឯងនៅទីនេះ!»**

ពួកយើងបានអោបគ្នានៅក្នុងចំណោមមនុស្សឯទៀតដែលនៅទីនោះ។

ចាន់ណារិនឯងនៅមានចាំស៊ីណាតដែរឬទេ? ស៊ីណាតមួយដែលធ្លាប់ធ្វើការជាមួយពួកយើងនោះណា?នៅឯសណ្ឋាគារអាំងទែដែលគេ កាលនោះជាអ្នកគិតលុយនៅឯការិយាល័យមុខ។ ស៊ីណាតមានប្រពន្ធនិងកូនមួយដែលគ្នាបានប្រាប់ចាន់ណារិនឯង ហើយគេស្លាប់ដោយសារតែគ្រោះថ្នាក់ចរាចរ។

ចាន់ណារិនឯងនៅចាំទេកាលមុនយើងបានទៅ ញាំអាហារនៅក្នុងហាងរបស់គេជាមួយ រិទ្ធី





និងបូរ៉ានោះ។

នៅពេលដែលគ្នាបានជួបគេនៅឋាននរក ពួកយើងទាំងពីរមានសេចក្តីរីករាយណាស់ តែស៊ីណាតមិនបាននិយាយរឿងរ៉ាវរបស់គេមកគ្នាច្រើនពេកទេ ព្រោះគេត្រូវជាប់រវល់និយាយរៀបរាប់ពីកិច្ចការទាំងឡាយនៅក្នុងឋានរបស់គេឲពួកយើងស្តាប់ ពួកយើងដែលទើបតែស្លាប់ទើបតែស្គាល់អ្វីទៅដែលហៅថាឋាននរកនោះ។ ទោះយ៉ាងណាគេបានសន្យាថានឹងនិយាយគ្នាឲបានច្រើននៅក្រោយពេលដែលការកំសាន្តនៅឋាននរកនេះ បានបញ្ចប់ជាមួយអ្នកទាំងអស់គ្នា។

ស៊ីណាតបាននាំពួកយើងថ្មីទាំង១០នាក់ចុះមកឋាននរកខាងក្រោមដែលពេលនោះបុទមវត្តីមិនបានមកជាមួយនិងគ្នាទេ ពួកនាងនៅចាំគ្នានៅខាងលើ។

នៅតាមផ្លូវស្ងាត់ងងឹតឈឹង គួរឲខ្លាចនោះ ស៊ីណាតបាននាំផ្លូវពួកយើងចុះមកមើលឋាននរកម្តង មួយៗតាមការហោះសន្សឹមៗរបស់ពួកយើង។មកដល់កន្លែងមួយស៊ីណាតបាននិយាយថា៖

**«នេះជាឋាននរកជាន់ទីមួយដែលធ្វើទារុណកម្មចំពោះមនុស្សទាំងឡាយណាដែលមានកម្មពារតិចតួចបំផុត នៅមុនពេលដែលពួកគេត្រូវចាប់ផ្តើមកើតជាមនុស្សលោកសារជាថ្មី»**

ស៊ីណាតបានឈប់បន្តិចហើយបន្តទៀតថា៖

**«សូមប្រាប់ពួកអ្នកទាំងអស់គ្នាដែរថា សំរាប់អ្នកទោសនៅឋាននរកនេះ មានអ្នកខ្លះរស់នៅពី១០ទៅ២០ឆ្នាំហើយក៏មានអ្នកខ្លះរស់នៅរាប់លានឆ្នាំផងដែរ។ នៅពេលដែលពួកគេរួចទោសពីទីនេះ គឺដាច់ខាតត្រូវត្រលប់ទៅកើតនៅឋានមនុស្សលោកវិញ ដើម្បីសាងកុសលសារជាថ្មីសំរាប់អនាគតជាតិ»**

នៅឋាននរកទីមួយនោះ ពួកយើងបានឃើញមនុស្សរាប់លាននាក់ ដែលកំពុងត្រូវទទួលទារុណកម្ម។ ពួកគេត្រូវបានគេយកខ្សែយកមកព្យួរនិងកឲផុតពីដី។ ពួកអ្នកទោសទាំងនេះត្រូវមានកម្មដោយសារតែពួកគេកាលនៅរស់ចូលចិត្តនិយាយដើមគេ ឬរករឿងឈ្លោះប្រកែកគេជាដើម។ពួកគេទាំងនេះត្រូវបានព្យួរកទៅតាមរយៈ កាលដែលគេបានសាងកម្ម។ពិតណាស់នៅទីនោះមាននាក់ទោសរាប់សែននាក់បានកំពុងតែព្យួរករណ្ដឹងរណោកដូចជាសត្វជ្រូក។

ពួកយើងដែលមានស៊ីណាតនាំផ្លូវនោះបានចុះមកដល់ឋាននរកទីពីរ ដែលនៅទីនោះវាពិតជា

គួរឲអាសូរដល់អ្នកទោសទាំងឡាយដែលកំពុងតែត្រូវបានគេដាក់ឲឈរ ដោយឲដងខ្លួនផ្អែកសំរាប់ដាក់កនិងដៃទាំងពីរចូលទៅនិងបន្ទះក្តារមួយ។ វាហាក់បីដូចជារឿងចិនដែលគេចាប់អ្នកទោសយកទៅប្រហារជីវិតដែរ។ តែអ្នកទោសនៅឋាននរកជាន់ទីពីរនេះ គ្រាន់តែបានគេគៀបកដៃទាំងពីរព្រមទាំងក្បាលរួចហើយត្រូវបានគេចាប់ដកកញ្ចកទាំងសងខាងតែប៉ុណ្ណោះ។ ឱពុទ្ធោអើយ! នៅពេលដែលគ្នាឃើញឈាមហូរនៅពេញម្រាមដៃរបស់អ្នកទោស ដែលកំពុងតែធ្លាក់មកខាងក្រោម គ្នាពិតជាមានការឈឺចាប់ជំនួសពួកគេណាស់។ អ្នកទោសទាំងនេះភាគច្រើនជាមនុស្សមានកម្មចូលចិត្តលួចរបស់ទ្រព្យអ្នកដ៏ទៃ ឬខ្មែរយើងហៅថាមានដៃមានជើងនោះ។ នៅក្នុងបន្ទប់ទារុណកម្មនិមួយៗ អ្នកទោសទាំងឡាយត្រូវបានគេធ្វើទោសគួរឲព្រឺឆ្អឹងក្បាល។ ពួកយើងបានបន្តមកឋាននរកទីបីទៀត ដែលនៅទីនោះគ្នាលឺតែសំលេងស្រែកថ្ងូរទ្រហោយំនិងការឈឺចាប់។ អ្នកទោសនៅឋានទីបីនេះ បើតាមគ្នាស្មានវាពិតជាពិបាកទ្រាំណាស់ព្រោះត្រូវគេចងដៃចងជើងបញ្ឈរហើយមានមេគុកម្នាក់វាយសំពងនិងខ្សែរតីដែលទំងន់ខ្សែរនោះបានធ្វើឲអ្នកទោសបែកឈាមពេញនិងខ្លួន។ហើយពេលខ្លះទំងន់នៃខ្សែរតីនេះបានវាត់រហូតដល់ដាច់សាច់ចូលទៅដល់ក្នុងឆ្អឹងលៀនចេញមកខាងក្រៅទៀតផង។ គ្នាពិតជារន្ធត់ពេកកន្លងនៅពេលដែលបានលឺសំលេងខ្សែរសួរ «ខ្វាច់ៗ» ចេញពីដៃមេគុក។ ពួកគេទទួលទារុណកម្មបែបនេះដោយសារតែកាលពីពួកគេនៅរស់ ពួកគេបានលួចទៅចាប់រំលោភប្រពន្ធគេកូនគេជាដើម ជាទូទៅជាប្រភេទអ្នកទោសខាងផ្អែកផ្លូវភេទ។

យើងបានចេញពីទីនោះហើយឆ្ពោះសំដៅមកកាន់នរកទីបួនម្តង។ ចាន់ណារិនអ្ហើយ! ពីឋាននរកមួយទៅឋាននរកមួយវាពិតជាគួឲខ្លាចផ្សារណាស់។អំពើរទារុណកម្មវាពិតជាសាហាវជាងពួកខ្មែរក្រហមទៅទៀត តែគ្រាន់ថានៅទីនេះគេធ្វើសំរាប់តែមនុស្សអាក្រក់តែប៉ុណ្ណោះ។ នៅក្នុងនរកទីបួននេះ គឺគេយកអ្នកទោសមកចងផ្តេក គេចងក្បាលគេចងពោះ គេចងជើងរួចហើយគេចាប់ផ្តើមទាញខ្សែរបណ្តោយខ្លួនមួយដើម្បីឲខ្លួនអ្នកទោសនោះត្រូវដាច់ពីគ្នាជាចំរៀកចំរៀក។ គ្នាស្ទើរតែមិនជឿនៅលើកែវភ្នែករបស់គ្នាទេ នៅពេលដែលឃើញខ្សែរគាន់តែតឹងហើយខ្លួនអ្នកទោសកាន់តែរហែកដាច់ចេញពីគ្នា។





ពេលដែលដាច់ខ្លួននោះហើយ ដែលឈាមបានបាញ់ចេញនៅគ្រប់ទីកន្លែងនៃសរីរាង្គកាយ។ ពុទ្ធោអើយ! វាហាក់បីដូចជាស្បោងទឹកមួយដែលត្រូវផ្ទុះធ្លាយដោយសារតែមានម្ជុលបានចាក់ទំលាយ។អ្នកទោសនេះបើតាមស៊ីណាតនិយាយគឺសុទ្ធតែជាអ្នកទោសដែលកេងប្រវ័ញ្ចន៍បងប្អូនឯងឪពុកម្តាយខ្លួន ធ្វើបាបក្រុមគ្រួសារដើម្បីដណ្តើមទ្រព្យពីគ្នាជាដើម។ គ្រប់ពេលដែលគ្នាបានលឺសំលេងស្រែកថ្ងូររបស់ពួកគេ វាពិតជាគួរឲអនិច្ចាណាស់។

ពួកគ្នាបានចុះបន្តមកទៀតនៅឯឋាននរកទី៥ នៅទីនោះវាកាន់តែសាហាវថែមទៀត។ អ្នកទោសទាំងអស់ត្រូវនៅដាច់ពីគ្នា ហើយម្នាក់ៗត្រូវបានគេលើកខ្លួនបន្ថោកទៅនិងដែកចុងស្រួចថ្មឹងម្យ៉ាងចំកណ្តាលទ្រូង រួចព្យួរទៅខាងលើ។ ពួកគេទាំងនេះពិតជាមានការឈឺចាប់ណាស់គេស្រែករហូត។ ពួកគេហាក់បីដូចជាសាច់គោមួយដុំដែលត្រូវបានគេដាក់បន្ថោកទុកលក់ឲអតិថិជន។ ឈាមរបស់ពួកគេបានហូរតក់ៗតាមរយៈចំរឹងដែកដែលព្យួរពួកគេ ហើយសំរាប់អ្នកខ្លះទៀត គ្នាបានឃើញមានសត្វកណ្តុរកំពុងតែប៉ឹតជញ្ជក់ឈាមពីខ្លួនផង។ ពួកកណ្តុរទាំងនេះក៏បានកកេរគ្រឿងក្នុងរបស់អ្នកទោសផងដែរបើអ្នកទោសនោះដេកលក់ឬក៏សន្លប់។ អ្នកដែលទទួលទោសទាំងនេះដោយសារតែពួកគេមានបាបដោយបានកាត់សេចក្តីខុស ពិសេសនៅខាងផ្អែកតុលាការដែលកាត់ពីល្អមកអាក្រក់ពីខ្មៅមកសជាដើមដោយសារតែចង់បានលុយសំណូក ដែលទាំងនោះគ្រាន់តែជាក្រដាសប៉ុណ្ណោះ។

គ្នាមកដល់ឋាននរកទី៦វិញ បានឃើញមនុស្សរាប់រយនាក់កំពុងតែឈរតំរង់ជួរគ្នា ទុកឲអ្នកមេទារុណកម្មកាត់ករបស់ពួកគេម្នាក់ម្តងៗ។ ពួកគេទាំងនេះត្រូវយកក្បាលរបស់ពួកគេ សកទៅនិងប្រលោះឈើរមួយដែលល្មមនិងក្បាលមនុស្សម្នាក់។ មេទារុណកម្មកាលបើក្បាលបានចូលមកដល់ហើយ គេតាំងបិតប្រលោះឈើនោះ ហើយទាញដែកទំងន់ប្រមាណជាមួយតោនឲធ្លាក់បណ្តាច់កនោះម្តងមួយៗ។ នៅទីនោះវាបានក្លាយទៅជាឋាននរកក្រហម ព្រោះតែមានឈាមបានបាញ់ ចេញគ្រប់កន្លែងទាំងអស់។ អ្នកដែលត្រូវកាត់កដោយទំងន់ដែកមួយតោននេះគឺដោយសារតែពួកគេ កាលពីនៅរស់ប្រកបមុខរបរប្លន់សំលាប់មនុស្ស ហេតុដូចនេះហើយទើបពួកគេត្រូវទទួលទារុណកម្មទាំងនេះវិញ។

គ្នាពិតជាក្ដៅខ្លួនអស់ហើយនៅពេលដែលបានឃើញអំពើរដ៏សាហាវទាំងនេះ។

គ្នាមើលបណ្ដើរគិតបណ្ដើរប្រសិនបើគ្នាធ្លាក់ទៅក្នុងសភាពបែបនេះវិញ តើគ្នាពិតជាវេទនាយ៉ាងណាទៅ? គ្នាពិតជាខ្លាច ហើយគ្នាពិតជាមិនចង់ឱនរណារម្នាក់នៅក្នុងគ្រួសាររបស់គ្នាមិត្តភក្ដិគ្នា ជួបទារុណកម្មបែបនេះទេ។ គ្នាទន្ទិញជាប់តែមាត់ថា៖

«ពុទ្ធោៗ»

អ្នកដែលរួមដំណើរជាមួយគ្នា ពួកគេក៏មិនខុសពីគ្នាដែរ ម្នាក់ខ្លាចញញើតហើយគ្រវីក្បាលឲតគាត់។

ពួកយើងបានបន្តមកកាន់នរកទី៧ទៀតដែលនៅទីនោះគ្នាបានសង្កេតឃើញមានអ្នកទោសម្នាក់នៅក្នុងបន្ទប់មួយដាច់ដោយឡែកពីគេ។ នៅក្នុងបន្ទប់នោះ មានទំហំប្រមាណតែកន្លះម៉ែត្របួនជ្រុងតែប៉ុណ្ណោះហើយប្រកបដោយចំរូងដែកនៅជុំវិញស្ដេកស្ដះ។ អ្នកទោសនេះត្រូវឈរនៅចំកណ្ដាលចំរូងស្រួចៗទាំងនោះ។ គេមិនអាចរើខ្លួនរួចបានទេសូម្បីតែបន្តិច បើមិនដូចនេះទេគេនឹងត្រូវចំរូងចាក់ជុំវិញខ្លួនចេញឈាមហូរហាមមិនខាន។ ពួកអ្នកទោសប្រភេទនេះ ត្រូវនៅឈរ ទទួលការវេទនាទាំងនេះ រហូតដល់តែពួកគេរួចពីកម្មទាំងឡាយដែលពួកគេបានសាងកន្លង។ ស៊ីណាតក៏បានប្រាប់ពួកយើងដែរថាអ្នកជាប់ទារុណកម្មនៅឋានទី៧នេះរហូតដល់ជាន់ទី១០គឺសុទ្ធតែជាអ្នកទោសដែលត្រូវជាប់លើសពីពាន់ឆ្នាំឡើងទៅ ហើយក៏មានអ្នកខ្លះលើសពីលានឆ្នាំផងដែរ។ ពួកគេត្រូវនៅទីនេះរហូតដល់តែរួចផុតនិងអាលអាចចាប់កំណើតជាមនុស្សសារជាថ្មី។ អ្នកដែលនៅជាប់នៅជាន់ទី៧នេះ គឺភាគច្រើនជាអ្នកនយោបាយដែលចូលចិត្តនិយាយកុហក បោកប្រាស់ហើយសុខចិត្តសំលាប់គេឯងមិនថាសមាជិកខ្លួនឬក៏អ្នកដ៏ទៃ ឲតែខ្លួនបានឈ្នះនិងអាចរក្សារអំណាចបន្ត។

ចូលមកដល់ឋាននរកទី៨វិញម្ដងដែលអំពើរទារុណកម្មកាន់តែយង់ឃ្នងទៅទៀត។ នៅទីនេះគេយកអ្នកទោសមកចងដែចងជើងហែកចេញពីគ្នា។ ដងខ្លួនរបស់អ្នកទោសបានចងផ្ដោបទៅនិងបន្ទះក្ដាផ្ដេកមួយ ដោយអ្នកទោសនោះមិនអាចកំរើកបានឡើយ។ នៅពីលើមុខ និងដងខ្លួនរបស់គេ មានកាំបិតមួយដ៏ធំយោលទៅយោលមកចុះឡើងៗ។ មុខកាំបិតដ៏មុតស្រួចថ្លានោះ បានទំលុះ





ពាក់កណ្ដាលមុខ ពាក់កណ្ដាលខ្លួនរបស់អ្នកទោសរួមទាំងអវយវៈ ទៅតាមការយោលរបស់មុខកាំបិត។ វាពិតជាគួរឲស្រៀវណាស់ទៅហើយនៅពេលដែលយើងយកកាំបិតមកប៉ះនិងថ្ពាល់ចុះនៅពេលដែលកាំបិតដ៏ធំនេះមកអូសកាត់ជាច្រើនរាប់លានដងនោះ តើវាមានការឈឺចាប់យ៉ាងណា? គួរឲរន្ធត់មិនគួរឲមើលឡើយនូវទារុណកម្មទាំងនេះ។ ពេលដែលកាំបិតបានយោលម្ដងៗ ឈាមបានបាញ់ចេញពីដងខ្លួនរបស់អ្នកទោសដែលធ្វើឲពួកគេស្រែករកអស់ហើយឪពុកម្ដាយរបស់គេឲមកជួយ។

កំពុងតែសំលឹងមើលទៅអ្នកទោសម្នាក់ស្រាប់តែមានគ្នាយើងម្នាក់បានស្រែកឡើងថា៖

**«អ៊ំ ផេងមែនទេ?»**

អ្នកទោសដ៏កំសត់មិនអាចក្រលេកមើលម្ចាស់សំលេងបានទេ គាត់បានត្រឹមតែលឺហើយឆ្លើយទាំងឈឺផ្សារមកថា៖

**«គឺអ៊ំមែន ជួយអ៊ំផង អ៊ំឈឺណាស់ក្មួនអើយ!»**

គ្រាន់តែបានលឺពាក្យប៉ុណ្ណោះហើយស្គាល់ថា ជាអ៊ំរបស់ខ្លួនមែននោះគ្នាយើងនោះបានស្រុតជើងដួលមួយរំពេច។ ពេលនោះគ្នាបានជួយគ្រានាងជាប់នៅនិងដៃមិនឲដួលទាន់ទេ។ ហើយនៅពេលនោះដែរក៏មានគ្នាយើងម្នាក់ទៀតបាននិយាយថា៖

**«លោកម្ចាស់សេនាឯក ខ្ញុំលែងចង់មើលបន្តទៅទៀតហើយ ប៉ុណ្ណឹងចុះបានហើយ ខ្ញុំចង់ទៅសមាធិវិញនឹងអាលបានទៅកើតជាតិថ្មីប្រសើរជាង»** គាត់និយាយបណ្ដើរទាំងថ្ងូរបណ្ដើរម្នាក់ៗនៅពេលនោះកាលបើបានលឺសំណើរនេះភ្លាមបាននាំគ្នាងក់ក្បាលយល់ព្រមថាពួកយើងទាំងអស់គ្នាមិនគួរទៅមើលទារុណកម្មទាំងនោះបន្តទៀតទេ។ ដោយមានការឯកភាពគ្នាយ៉ាងដូចនេះ ស៊ីណាតបានយល់ព្រមហើយនាំពួកយើងមកកន្លែងដើមវិញ មកជួបនិងលោកឧបរាជដើម្បីទទួលសៀវភៅធម៌។

នៅតាមផ្លូវត្រលប់មកវិញនោះគ្នាបានឆ្លៀតសួរពីមូលហេតុកម្មដែលអ្នកទទួលទោសនៅឋានទី៨នោះបានសាង។ គេបានប្រាប់គ្នាថាពួកអ្នកទោសទាំងនេះគឺសុទ្ធតែពពួកឧក្រិដ្ឋកម្ម សង្គ្រាម។ ជាមនុស្សដែលបានសំលាប់មនុស្សរាប់ម៉ឺនសែននាក់។ ពួកឧក្រិដ្ឋជនទាំងនេះ ភាគច្រើនត្រូវទទួលទារុណកម្មលើសពីរាប់លានឆ្នាំឯណោះ។ និយាយបានបន្តិចពួកគ្នាបានមក ដល់កន្លែង

ចាស់ល្អម។ហើយម្នាក់ដែលបានបាត់បង់ស្មារតីនោះក៏បានដឹងខ្លួនវិញដែរ។

នៅពេលដែលបានជួបលោកឧបរាជជាលើកទីពីរនេះ លោកបានប្រគល់គម្ពីធម៌ដល់ពួកយើងម្នាក់មួយៗ ហើយចុងក្រោយនោះលោកក៏បានផ្ដែផ្ដាំឲពួកយើងរក្សានូវអ្វីដែលពួកយើងបានឃើញអំបាញ់មិញនេះទុកនៅក្នុងខ្លួនជាប់ជានិច្ចមុននឹងចង់ធ្វើអំពើបាបអ្វីមួយ។ លើសពីនេះទៅទៀតលោកផ្ដាំហើយផ្ដាំទៀតឲពួកយើងប្រឹងប្រែងទន្និញធម៌ ជៀសវាងទៅធ្វើបាបអ្នកដទៃនាំឲមានកម្មជំពាក់បន្តទៅទៀត។ ពួកយើងទាំងអស់ក្រោយពីបានស្ដាប់បណ្ដាំរបស់លោកឧបរាជហើយ បានហោះចេញពីទីនោះរៀងៗខ្លួនម្នាក់ម្ដងៗជាប់តែកន្ទុយគ្នា។ លើកលែងតែគ្នានិងបុទមវត្តីប៉ុណ្ណោះដែលនៅបន្ត ដោយសារតែស៊ីណាតចង់និយាយលេងជាមួយនិងគ្នា។

នៅក្នុងការសន្ទនាតែ៤នាក់នោះ ស៊ីណាតបានប្រាប់មកគ្នាថា នៅក្រោយពីគេស្លាប់មកគេពិតជាមានការអាណិតប្រពន្ធនិងកូនគេណាស់កាលពីទើបនិងស្លាប់ថ្មីៗ ប៉ុន្តែក្រោយមកគេបានប្រសើរមកវិញនៅពេលដែលគេបានយល់ថាជីវិតវាគ្រាន់តែជាស្រមោលមួយប៉ុណ្ណោះ។

ស៊ីណាតក៏បានប្រាប់គ្នាផងដែរថាតាមពិតគេត្រូវទៅឋានសួគ៌ឯណោះ តែដោយសារគេចង់ចាំប្រពន្ធនិងកូនរបស់គេទើបគេសុខចិត្តព្រមនៅបំរើស្ដេចយមរាជមួយរយៈសិន។ ទំរាំនិងកូនប្រពន្ធរបស់គេមកដល់នៅប៉ុន្មានជាង៧០ឆ្នាំខាងមុខនេះ។

ជាការពិតណាស់ចាន់ណារិន! នៅពេលដែលគ្នាបានជួបស៊ីណាត អ្នកដែលយើងធ្លាប់ស្គាល់ដូចនេះ គ្នាពិតជាសប្បាយចិត្តណាស់ឯស៊ីណាតវិញក៏មិនខុសពីគ្នាដែរ។ ស៊ីណាតបានបញ្ជាក់ប្រាប់ គ្នាជាចុងក្រោយថា សព្វថ្ងៃនេះគេអស់ហើយនៅការចង់បាននិងកាមកិលេសទាំងឡាយ។ រូបរបស់គេបានសុខហើយនៅពេលនេះ។

ទីបញ្ចប់នៅមុនពេលដែលគ្នាលាគេមកនោះ ស៊ីណាតបានផ្ដាំគ្នាឲទៅមើលប្រពន្ធនិងកូនគេផងហើយប្រាប់ឲពួកគេឈប់ខ្វាយខ្វល់ពីរូបខ្លួនព្រោះមិនយូនោះទេ ពួកគេនិងបានជួបគ្នាក្នុងពេលដ៏ឆាប់ខាងមុខនេះមិនខាន។

ពីរនាក់យើងបានអោបលាគ្នាជាចុងក្រោយ ដោយសង្ឃឹមថាពួកយើងនិងមានឱកាសជួបគ្នានៅពេលក្រោយទៀតមិនខាន។

ចប់សំដីគ្នានិងបុទមវត្តីបានហោះបណ្ដែតខ្លួនមកខាងលើវិញដោយទុកឲស៊ីណាតនៅឈរមើល





ពួកយើងទាំងអាល័យបំផុត។ ពួកយើងទាំងបីបានធ្វើដំណើរដូចជាធម្មតាដោយបុទមវត្តីនៅអែមគ្នាសងខាង តែពេលនេះគេមិនចាំបាច់កាន់ដៃគ្នាទៀតទេ ព្រោះតែគ្នាអាចហោះហើរដោយខ្លួនគ្នាបានហើយ។

មកដល់មុខផ្ទះគ្នាក្នុងវត្តសុភាឃួននៅវេលាម៉ោងប្រមាណជា៤:៣០ព្រឹកបុទមបានបន្លឺឡើងថា៖

«មកដល់កន្លែងដែលបងត្រូវសិក្សាទន្និញធម៌ហើយ»

«នៅកន្លែងណា?» គ្នាបានសួរទៅនាងវិញទាំងខំបើកភ្នែករំពៃរក

«នៅក្នុងម្លូសនេះឯង»

«ម្លូសនេះមែនទេ?» គ្នាសួរទាំងបារម្ភដោយសំលឹងមើលទៅក្ដាម្លូសនារាត្រីដ៏ស្ងាត់ជ្រងំ

«ត្រូវហើយបងគឺនៅក្នុងម្លូសនិងផ្ទះនេះឯងដែលបងត្រូវនៅក្នុងរយៈមួយរយថ្ងៃខាងមុខ»

នៅពេលដែលនាងបានបញ្ជាក់យ៉ាងច្បាស់ដូចនេះ គ្នាបានរំអ៊ូយទៅប្រាប់នាងវិញថា៖

«តើឲខ្ញុំទន្និញធម៌ម្ដេចនិងចូលពួកនាងមើលទៅមើលសាកសពរបស់ខ្ញុំកំពុងតែស្អុយរលួយមានក្លិនដ៏អាសោចនៅលើផ្ទៃមុខទៀត ដងខ្លួននិងរាល់អវយវៈទាំងអស់ ដែលកំពុងតែចោះទំលុះស៊ីដោយសត្វល្អិត។ លើសពីនោះទៀត នៅមានឈាមនិងទឹករងៃទាំងឡាយដែលកំពុងតែហូរជ្រៀបសើមពេញបាតក្ដាម្លូស តើពួកនាងនៅតែឲខ្ញុំចូលទៅទីនោះទៀតមែនទេ?»

កាលបើបានលឺការរៀបរាប់របស់គ្នា នាងទាំងពីរមិនបានជួយខ្វាយខ្វល់និងគ្នានោះទេ តែបែរជានាំគ្នាសើចទៅវិញ វត្តីបានបន្តមកវិញថា៖

«សូមបងកុំគិតដូចនេះឲសោះ នេះគ្រាន់តែជារូបជាតិមុនតែប៉ុណ្ណោះ។ តែបងមើលដួងព្រលឹងរបស់បងទៅមើល តើស្អាតជាងជាមនុស្សឬយ៉ាងណា?»

គ្នាក្រលេកមកមើលព្រលឹងគ្នាវិញ ឃើញថាគ្នាស្អាតជាងមុនដូចតែនាងថាមែន តែយ៉ាងណាគ្នានៅតែធ្វើមាត់ស្ងួញនៅពេលដែលក្រលេកទៅមើលសាកសពឯក្នុងម្លូសនោះ។

វត្តីបានបន្តទៅទៀតថា៖

«ដោយសារបងជាមនុស្សមិនធ្វើបាប នៅពេលដែលបងចូលគេងនៅក្នុងម្លូសនេះ ក្លិនឆ្អេះឆ្អាបទាំងឡាយ និងក្លាយទៅជាក្លិនក្រអូបឈ្ងុយឈ្ងប់វិញមិនខាន ឯសត្វល្អិតនោះសោត និងក្លាយ

ទៅជាបុប្ផាគ្រប់ទងនឹងផុះនៅជុំវិញបងមិនខានឡើយ។ ទឹកងងៃវិញម្តងនឹងក្លាយទៅជាទឹកដីគ្រជាក់ម្យ៉ាងសំរាប់ស្ពុំផ្លូងចិត្តបងឲកាន់តែស្គាល់នូវធម៌ទាំងឡាយ ហើយនឹងធ្វើឲបង កាន់តែមានចិត្តកាយស្អាតស្អំទៅទៀត»

«ពិតមែនឬ?» គ្លាសួរបញ្ជាក់

«មែនណាបង»

«ចុះពួកនាងវិញនឹងមកនៅជាមួយខ្ញុំទីនេះឬទេ?»

«មិនបានទេបង ពួកខ្ញុំមានតួនាទីតែប៉ុណ្ណឹងទេ តែបើបងមានសំនួរនិងខ្វះខាតអ្វីនោះបងគ្រាន់តែហៅឈ្មោះពួកខ្ញុំទៅ ពួកខ្ញុំនឹងមកដល់ទីនេះភ្លាម»

«ហ៊ឹម! ខ្ញុំនឹងពិតជាអផ្សុកណាស់ប្រសិនបើមិនមានពួកនាងនៅទីនេះជាមួយខ្ញុំទេនោះ»

«កុំភ័យណាបង! នៅពេលដែលបងដក់ចិត្តក្នុងការទន្និញធម៌ បងនឹងបាត់អស់ហើយនូវការនឹករលឹកចំពោះនរណាម្នាក់ ក្នុងចិត្តរបស់បងមានតែភាពស្ងប់ស្ងាត់តែប៉ុណ្ណោះ»

បុទមបន្តទៅទៀតថា៖

«ដល់វេលាដែលពួកខ្ញុំត្រូវទៅហើយបង ព្រោះមេឃកាន់តែជិតភ្លឺណាស់ទៅហើយ»

«សូមបងប្រឹងប្រែងសិក្សាទន្និញធម៌ឲបានល្អ ហើយកុំប្រព្រឹត្តិអំពើរបាបឲសោះនៅពេលដែលបងមានសេរីភាពបែបនេះ។ បងត្រូវមានសង្ឃឹមថានៅពេលប៉ុន្មានទៀតតែប៉ុណ្ណោះ បងនឹងបានរួចពីទុក្ខទោសទាំងនេះមិនខាន» វត្តីនិយាយ គ្លាមើលមុខពួកគេដោយងក់ក្បាលតិចៗ

យល់ព្រម

«សូមបងទទួលបានជោគជ័យនៅក្នុងការបំពេញភារកិច្ចនេះ ដល់វេលាកំណត់១០០ថ្ងៃនៃការស្លាប់របស់បង ពួកខ្ញុំនឹងមកទទួលបងទៅវិញ»

ចប់សំដីបានត្រឹមនេះពួកនាងក៏បានរលាយខ្លួនបាត់មួយរំពេចទៅ ទុកឲគ្លាឈរផ្ទឹងតែម្នាក់ឯងសំលឹងទៅមើលសាកសពក្នុងម្ឈូសដែលកំពុងតែហើមស្អុយរលួយគួរខ្ពើមរអើម។ ទោះយ៉ាងណាក៏ដោយគ្លាបានបណ្តែតខ្លួនចូលទៅក្នុងម្ឈូសក្រោមដីនោះដោយសន្សឹមៗ ហើយគ្លាចាប់ផ្តើមដេកចូលទៅក្នុងរូបដើមរបស់គ្លាវិញ។

ជាការពិតណាស់ចាន់ណារិន! យប់ដំបូងនោះ វាពិតជាមានក្លិនស្ទើរដកដង្ហើមមិនរួច វាជាក្លិន





ដែលមិនខុសពីផ្កាដែលកំពុងតែស្អុយរលួយនៅក្នុងថូអស់រយៈពេលជាច្រើនឆ្នាំនោះទេ។ គ្លាមិនបានមានការឈឺចាប់ដោយការខាំ ចោះរបស់សត្វល្អិតទេ តែក្លិនរបស់វាបានធ្វើឲគ្លាខ្លាចខ្លាចស្ទើតែស្ទុះចេញពីម្ឈូសទៅហើយ។ គ្លាខំបិតភ្នែកអោបសៀវភៅធម៌ដែលត្រូវទន្និញដោយស្ងៀមស្ងាត់។ហើយនៅពេលដែលមានពន្លឺព្រះអាទិត្យបញ្ចេញកាំរស្មីនៅលើទីបលោកនោះ អារម្មណ៍របស់គ្លាក៏បានរលត់នៅពេលដំណាលគ្នានោះដែរ វាហាក់បីដូចជាគ្លាបានគេងលក់នៅឋានមនុស្សលោកតចឹងដែរ។

នៅថ្ងៃទីមួយនៃការមកតាំងសិល្ប៍នៅក្នុងផ្នូររបស់គ្លា គ្លាបានស្រម៉ៃឃើញរឿងអឌិតរបស់គ្លាដែលបានធ្វើឲគ្លាបានដឹងកាន់តែច្បាស់ថា កាលពីជាង៥០០ឆ្នាំមុន គ្លាគឺជាដង្ហៅម្នាក់ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភនៅក្នុងភូមិមួយនាខេត្តកំពង់ចាម។ គ្លាមានភរិយាបីរូបមានឈ្មោះបុប្ផា គីរូបដានិតសព្វថ្ងៃនេះនិងបុទមវត្តី។ ប្អូននាក់ប្តីប្រពន្ធយើងមានកូនបីនាក់ដែរ។ ពួកយើងរស់នៅបានសុខសប្បាយណាស់មិនដែលចេះមានជំលោះម្តងណាទេ។

នៅគ្រប់ពេលខែបុណ្យទានម្តងៗ គ្រួសាររបស់យើងតែងតែធ្វើបុណ្យដាក់ទានមិនដែលលស់លើសពីនោះទៅទៀតគ្រួសារយើងតែងបានជួយដល់បងប្អូនទាំងឡាយណាដែលមានវិបត្តិទោះខាងផ្លូវចិត្តឬខាងផ្នែកថវិការក៏ដោយ។ នៅពេលនោះហើយដែលបានធ្វើឲអ្នកភូមិផងរបងជាមួយមានការចូលចិត្តរាប់អាននិងគ្រួសារយើងគួរជាទីកក់ក្តៅ ពួកគេតែងតែហៅគ្លាថាជាដង្ហៅបុណ្យ។ ក្នុងគ្រួសារគ្លានៅពេលនោះ មានអ្នកបំរើម្នាក់ឈ្មោះនាយប្រឹម។ ប្រឹមជាក្មេងជំទង់ដែលម្តាយឪពុករបស់គេបាននាំមករស់នៅបំរើក្រុមគ្រួសាររបស់គ្លាដើម្បី ដោះបំណុលដែលពួកគាត់ជំពាក់។ ទោះបើប្រឹមមានកម្មដោយឪពុកម្តាយលក់គេក៏ដោយ តែគ្រួសាររបស់គ្លាមិនដែលបានចាត់ទុកប្រឹមដូចជាខ្ញុំបំរើដាច់ថ្លៃម្តងណាទេ។ ពួកគ្លាតែងចាត់ទុកប្រឹមដូចជាកូនក្មួយទៅហើយ។

នៅពេលមួយបានមកដល់ ពេលដែលគ្លាកំពុងប្រលែងជាមួយកូនៗនៅខាងក្រោមផ្ទះនោះស្រាប់តែកូនច្បងរបស់គ្លាបានរត់ទៅជាន់ពស់វែកដំបូកដែលមានពណ៌ខ្មៅស្រិលដែលកំពុងតែពាក់គ្លាជាមួយនិងពស់មួយទៀតនៅពេលព្រលឹមយ៉ាងច្បាស់។ កាលបើបានប៉ះទង្គិចយ៉ាងដូច

នេះហើយ ពស់ទាំងពីរបានបើកវែកនិងសំលឹងមកដាក់កូនច្បងរបស់គ្នាយ៉ាងមាំជាទីបំផុត។ គ្នាដែរនៅមិនឆ្ងាយពីទីនោះបានធ្វើសញ្ញាឲកូនច្បងគ្នានៅស្ងៀមកុំកំរើកឲសោះបើមិនដូចនេះទេពស់នោះនឹងហក់ត្របាក់កញ្ចឹងកកូនមិនខាន។ នៅពេលដំណាលគ្នានោះដែរ គ្នាក៏បានធ្វើភ្នែកឲប្រឹមកៀសពស់ទាំងពីរនោះទៅម្ខាងឲឆ្ងាយ។ ប្រឹមកាលបើបានទទួលសញ្ញានេះហើយគេមិននៅស្ងៀមនោះទេ។ គេបានខំលូនសន្សឹមៗ តែមិនបានកៀសពស់នោះទេ គេបែទៅជាវាយសំពងយ៉ាងខ្លាំងចំពាក់កណ្តាលខ្លួនពស់ញីដែលធ្វើឲវាមិនអាចទៅណាបានទេ ឯអាឈ្មោលវិញនៅពេលនោះបានហក់ផ្ញោតបំរុងនឹងបំបែកភ្នែករបស់ប្រឹម តែត្រូវប្រឹមប្រលែងមួយដំបងឲពស់ឈ្មោលនោះទៅម្ខាងប្រមាណជា៥ម៉ែត្រ។ ដោយត្រូវមួយដំបងយ៉ាងដំណំយ៉ាងនេះពស់ឈ្មោលក៏បានវារត់បាត់ទៅទោះបើប្រឹមខំទៅរកទៀតក៏មិនឃើញដែរ។

ចំណែកឯពស់ញីវិញដែលមិនអាចទៅណាបាន ខិតខំស្រវេស្រវ៉ាចុះឡើងៗនៅពេញដី។

ពេលនោះភរិយាគ្នាទាំងបីបានមកដល់ល្មមហើយនាំគ្នាផ្អើលឆោឡោពីរឿងរ៉ាវទាំងនេះ។ ម្នាក់ៗមានការតក់ស្លុតគ្រប់គ្នានៅពេលដែលបានឃើញពស់ញីដ៏ធំនេះ។ ប្រឹមបានសួរមកគ្នាថាត្រូវយ៉ាងម៉េចជាមួយពស់ញីដ៏ធំនោះ? គ្នានៅស្ងៀមហើយគិតថាចង់យកពស់នេះទៅព្យាបាលឲបានជាសះស្បើយវិញ តែគំនិតនេះត្រូវបានភរិយាទីមួយរបស់គ្នា បុប្ផ ប្រកែកព្រោះតែនាងគិតថាពស់ទាំងពីរនេះពិតជាកាចសាហាវណាស់ ហើយបានសំលាប់អ្នកស្រុកក៏ច្រើនណាស់ដែរ។បុប្ផ បានបញ្ជាឲប្រឹមសំលាប់ពស់នោះចោលភ្លាម។ គ្នាមិនបានប្រកែកតបតឲខ្លាំងនោះទេព្រោះអ្វីដែលនាងនិយាយវាជាការពិតមែន ឯប្រឹមវិញបានធ្វើតាមលោកស្រីរបស់គេដោយវាយពស់នោះជាច្រើនដំបងរហូតដល់ក្តីមរណា។

នៅក្នុងផ្លូវតាំងសមាធិ គ្នាបានស្រមៃឃើញទៀតថានៅពេលដែលប្រឹមវាយសំពងពស់ញីនោះអាឈ្មោលវាមិនទៅណាឆ្ងាយឡើយ តាមពិតទៅវាកំពុងតែសំលឹងមកមើលពួកយើងទាំងកំហឹងបំផុតដែលបានសំលាប់មេញីរបស់វា។

សំរាប់គ្នានៅពេលនោះ គ្នាពិតជាអាណិតពស់ទាំងពីរនោះណាស់ដែលត្រូវព្រាត់ប្រាស់គ្នាយ៉ាងដូចនេះ។ គ្នាបានដឹងថានេះជាកំហុសរបស់គ្នាដែលបានបំបែកពួកគេទាំងពីរ តែអ្វីៗ គ្នាគ្រាន់តែ





ធ្វើដោយអចេតនានិងការពារកូនរបស់គ្នាតែប៉ុណ្ណោះ។

ក្រោយពីបានសំលាប់រួចហើយ គ្នាមិនបានដឹងលឺរឿងរ៉ាវទាំងនោះទៀតទេ ឯប្រឹមវិញគេបានយកពស់នោះទៅស្ងោរធ្វើម្ហូបក្លែមជាមួយនិងមិត្តភក្តិរបស់គេនៅក្នុងភូមិនោះទៅ។

បីថ្ងៃក្រោយមក នៅពេលព្រឹកព្រលឹមឡើង គ្នាឆ្ងល់ថាហេតុអ្វីបានជាមិនឃើញប្រឹមមកធ្វើការដូចសព្វដងយ៉ាងដូចនេះ? គ្នាបានចូលទៅមើលកូនខ្ទមរបស់គេដែលសង់មិនឆ្ងាយពីគេហដ្ឋានរបស់គ្នា។ នៅពេលនោះគ្នាបានឃើញគេកំពុងតែដេកស្លាប់ ទាំងខ្លួនប្រាណខៀវស្រងាត់។ នៅលើផ្ទៃមុខរបស់គេមានស្នាមខាំជាច្រើនកន្លែង។ហើយនៅចំសសៃកញ្ចឹងកនោះសោតក៏មានហូរឈាមយ៉ាងកក្លាក់។ គ្នាមិនដឹងថាពស់នោះបានខាំប្រឹមប៉ុន្មានដងនោះទេ តែផ្ទៃមុខនិងខ្លួនប្រាណរបស់គេបានសុស រហែកដាច់អស់ទៅហើយនូវស្នាមចង្កូមពស់ពិសដ៏សាហាវនោះ។ មុខប្រឹមមើលទៅពិតជាគួរឲខ្លាចជាទីបំផុត។ គឺសាកសពមួយដែលគ្នាពិតជាមិនដែលឃើញទាល់តែសោះ នៅពេលនោះហើយដែលគ្នាអាចដឹងថាកំហឹងអាឈ្មោលពិតជាមិនធម្មតានោះទេ។ តាមស្នាមការខាំបំបែកខ្លួនប្រាណរបស់ប្រឹម វាបានបង្ហាញយ៉ាងច្បាស់ថាពស់នោះពិតជាសាហាវនឹងឃោឃៅជាទីបំផុត។

គ្នាបានប្រាប់ឲគេយកសាកសពរបស់ប្រឹមទៅបូជានៅឯវត្តនៅពេលព្រឹកនោះដែរ។ តាមពិតទៅនៅយប់នោះមិនមែនមានតែប្រឹមប៉ុណ្ណោះទេដែលស្លាប់ដោយចង្កូមពស់នោះ គឺមានអ្នកភូមិ៥នាក់ទៀត ៥នាក់ដែលបានស៊ីសាច់ពស់ញីក៏ត្រូវស្លាប់នៅយប់តែមួយដែរ។ អ្នកភូមិកាលបើបានដឹងហើយ មានការអាណិតអាសូរដល់ប្រឹមនិង៥នាក់ឯទៀតគ្រប់ៗគ្នា ហើយពិសេសនាំគ្នាចងគំនុំថានឹងសំលាប់ពស់សាហាវនោះវិញឲទាល់តែបាន។ នៅថ្ងៃនោះ គ្នាមានអារម្មណ៍យ៉ាងច្បាស់ថាអាឈ្មោលនឹងមករករឿងក្រុមគ្រួសារគ្នាម្តងទៀតមិនខានពិសេសកូនច្បងគ្នានិងបុប្ផ។ វាប្រាកដជាមកព្រោះការសំលាប់ប្រឹមវានឹងមិនទាន់អស់ចិត្តវាឡើយ។

ដោយយល់ហេតុការណ៍ដូចនេះ គ្នាបានប្រកាសឲអ្នកភូមិទាំងអស់ជាពិសេសយុវជនក្លាហានមានគ្នាប្រមាណជា៣០នាក់ឲត្រៀមដំបងគ្រប់ដៃដើម្បីតាមសំលាប់សត្វពស់ដ៏ឃោឃៅនោះ។ នៅពេលថ្ងៃគ្នាបានចាត់ផែនការណ៍ឲពួកគេ លាក់ខ្លួននៅលើដើមឈើគ្រប់ៗគ្នា និងត្រៀម

ចំបើងសំរាប់ដុតបំភ្លឺ។

នៅពេលយប់មកដល់ គ្នាបានជំលៀសប្រពន្ធនិងកូនគ្នាទាំងអស់ឲមកស្នាក់នៅឯផ្ទះអ្នកស្រុកចំណែកឯអ្នកស្ម័គ្រចិត្ត រួមមានគ្នាជាអ្នកដឹកនាំនោះបាននៅបន្តចាំមើលការមកដល់ពស់ឈ្មោលនោះ។ភ្លើងចំបើងបានដុតបំភ្លឺព្រឹមៗនារាត្រីយប់ងងឹតឯពួកគ្នាឯនេះវិញបាននាំគ្នាមកទុំនៅលើដើមឈើនៅជុំទិសទាំងបួនដោយខំប្រឹងសំលឹងមិនហ៊ានប៉ប្រិចភ្នែកម្តងណាឡើយ។ ពួកគ្នាបានអង្គុយចាំតាំងពីព្រលប់រហូតដល់យប់ស្ងាត់ឈឹង គ្មានលឺសំលេងអ្វីទាំងអស់ ចន្ទះនិងចំបើងក៏នៅតែឆេះព្រាលៗ។ចាំបាត់ៗ មិនឃើញមានស្រមោលអ្វី អ្នកខ្លះងងុយគេងស្ទើរតែបើកភ្នែកមិនរួចទៅហើយ។ នៅពេលនោះគ្នាក៏បានឲពួកយើងពាក់កណ្តាលសំរាក និងពាក់កណ្តាលទៀតនៅបន្តការឃ្លាំមើល។ យប់កាន់តែជ្រៅ គ្មានលឺសំលេងអ្វីក្រៅពីខ្យល់បក់ស្លូវល្វើយៗ ហាក់ចង់បំពេរពួកយើងទាំងអស់គ្នាឲលង់លក់ រំពេចនោះសត្វពស់មួយក្បាលយ៉ាងធំមានពណ៌ខ្មៅក្រិបចាំងទៅនិងពន្លឺចំបើងភ្លៀកៗ។ ពស់នោះបានវារចេញពីកម្តោតព្រៃយ៉ាងលឿនឆ្វេវ ពីកម្តោតព្រៃដែលនៅខាងក្រោយផ្ទះរបស់គ្នា។

ពស់នោះមានទំហំធំស្ទើរតែប៉ុនអង្រែបុកស្រូវទៅហើយ ឯប្រវែងនោះសោតវែងប្រមាណជា១,៥០ម៉ែត្រ។ ពេលឃើញវាដំបូង ម្នាក់ៗមានការភ័យឡើងរួញខ្លួន ហើយក៏មានអ្នកខ្លះទៀតរាគអាចម៍រាគនោមនៅពេលនោះដែរ។ ពេលដែលពស់នោះបានមកដល់ទីធ្លាផ្ទះហើយ គ្នាបានស្រែកធ្វើសញ្ញាឲពួកយើងទៅដុតផ្អឹម ចំបើងដែលយើងបានត្រៀមទុកជាស្រេច។ចំបើងបានឆេះហើយវាបំភ្លឺយ៉ាងច្បាស់នៅមុខមាត់ពិតរបស់សត្វពស់នោះ។ ពួកយើងដែលនៅត្រៀមខ្លួនទាំងបួនទិស បានចេញព្រមៗគ្នាទៅព័ទ្ធជាប់។ វានៅចំកណ្តាលពួកយើង រេក្បាលចុះឡើង ហាក់មិនមានការភ័យនិងពួកយើងបន្តិចទេ។ ឃើញសភាពបែបមិនស្រួលដូចនេះ គ្នាបានស្រែកប្រកាសឲពួកយើងទាំងអស់គ្នាវាយសំពងឲឆាប់ ពួកគេបានធ្វើតាមគ្នាដោយម្នាក់ៗបានវាយទាំងមិនមើលមុខ តែត្រូវអ្នកខ្លះស្រែកទ្រហោយំនៅ ពេលដែលពិសពស់បានព្រួសចំកែវភ្នែករបស់ពួកគេ។ ទោះជាមានការព្រួសពិសយ៉ាងណាក៏ដោយ កំហឹងនៃអ្នកភូមិកាន់តែឆាបឆេះហើយនៅតែតស៊ូវាយសំពងនិងសត្វពស់នោះក្រាបជាប់និងដីរើទៅណាមិនរួច។

នៅពីមុខគ្នានិងបងប្អូនអ្នកភូមិ ពស់នោះនៅមិនទាន់ស្លាប់នៅឡើយទេ ភ្នែករបស់វាបានបោលសំឡឹងមកមើលគ្នាយ៉ាងជាប់ ហាក់ចង់ប្រាប់គ្នាថា វាខឹងនិងគ្នាណាស់! ដោយឃើញវាស្ទើររស់ស្ទើរស្លាប់យ៉ាងដូចនេះ គ្នាក៏សំរេចចិត្តវាយសំពងក្បាលរបស់វា៤ទៅ៥ដំបង ទើបវាស្លាប់ទៅ។

ក្រោយមកគ្នាមិនឲអ្នកណាយកវាមកស្ងោរបរិភោគនោះទេ គ្នាបានសុំជីវត្តយកវាមកកប់ឲបានត្រឹមត្រូវ ហើយនៅគ្រប់ពេលដែលគ្នាធ្វើបុណ្យ គ្នាតែងតែឧទ្ទិសផលបុណ្យទាំងឡាយដល់ពស់ទាំងពីរនោះ ហើយពិសេសបានសូមខមាលទោសពីឧបត្តិហេតុដ៏ខ្លោចផ្សារនោះថែមទៀត។ តែមានអ្នកណាដឹងថា ពស់នេះនៅតែតាមព្យាបាទគ្នា បន្តទៅទៀតនៅឋានមនុស្សលោកបើទោះជាគ្នាព្យាយាមធ្វើបុណ្យបញ្ជូនកុសលដល់គេទាំងពីរយ៉ាងណានោះក៏ដោយ។

និយាយពីគ្នាដែលកំពុងតែស្រម៉ៃនៅក្នុងផ្លូវនេះម្តង កាលបើគ្នាបានដឹងរឿងទាំងនេះហើយទើបគ្នាភ្ញាក់ខ្លួនថាឃាតករដែលបានប្រហារជីវិតគ្នានេះ តាមការពិតទៅគេគឺជាសត្វពស់មកចាប់កំណើតសោះ។ វាគឺជារឿងដែលបានកើតឡើងតាំងពី៥០០ឆ្នាំមកម្លេះ តែកំហឹងរបស់វានៅតែមិនអាចបំភ្លេចបាន ដោយវានៅតែមកតាមចងពារនិងគ្នាទៀត ទោះបើដឹងថាជាតិក្រោយវានឹងចុះនរករងកម្មវេទនាយ៉ាងណាក៏ដោយ។

ឱពុទ្ធោហើយ! គំនុំពិតជាបានធ្វើឲសត្វលោកវិនាសគ្មានថ្ងៃបញ្ចប់!

នៅក្នុងផ្លូវ គ្នាបានប្រាប់ខ្លួនគ្នាថា គួរតែគ្នាបញ្ចប់ការចងកម្មពារនេះតទៅ។ តាមពិតវាជាកំហុសរបស់គ្នាដែលបានបង្ករមុន។ គ្នាបានរំលឹកខ្លួនគ្នាថាពេលនេះវាសាកសមនិងគ្នាទទួលអំពើរនេះហើយ គ្នាក៏បានផ្សងផងដែរ សូមឲការសងសឹកទាំងនេះបានចប់ ហើយគ្នាក៏នឹងមិនទៅសំលាប់ឃាតករនោះដែរទោះបើគ្នាបានគិតពីមុនថានឹងត្រូវចងអាឃាតនោះ។

គ្នាបានបើកភ្នែកតែម្នាក់ឯងនៅក្នុងម្លូស នៅពេលនោះហើយដែលការខឹងរបស់គ្នាបានរសាយអស់រលីងដែលវាមិនបានដូចពីមុនដែលគ្នាតែងតែគិតទៅផ្លូវអាក្រក់។ តែពេលនេះអ្វីៗបានផ្លាស់ប្តូរអស់។ ចិត្តរបស់គ្នាហាក់មានសភាពស្ងប់គ្មានអំពើរហឹង្សារទៀតឡើយ។ គ្នាញញឹមនៅពេលដែលគ្នាមើលមកដួងព្រលឹងរបស់គ្នាដែលនៅតែមានសភាពស្រស់បំព្រង លើកលែងតែរូបដើមនៅក្នុងម្លូសតែប៉ុណ្ណោះដែលនៅតែរលួយរលេស។ ទោះបីជាគ្នានៅដេកនៅលើសាក

សពដែលមានក្លិនស្អុយអាសោចន៍សំរាប់មនុស្សលោកទាំងពួង

តែសំរាប់គ្នាវាបានក្លាយទៅជាក្លិនដ៏សែនឈ្ងុយឈ្ងប់ ជាក្លិនដែលមិនធ្លាប់បានជួបប្រទះ។ វាពិតជាក្រអូប ដែលគ្រាន់តែហិតក៏មានកំលាំងដែរ។ ចំណែកឯសត្វល្អិតដែលកំពុងតែស៊ីរូង ផ្ទៃក្នុងនោះវិញ នៅទីបំផុតវាបានក្លាយទៅជាមិត្តសំលាញ់របស់គ្នាទាំងអស់។ គ្នាបានតែពួកវា និងហើយនៅកំដរកំឡុងពេលនៅតាំងសិល្ប៍នោះ។

នៅយប់ដំបូងនៅពេលដែលគ្នាភ្ញាក់ដឹងខ្លួន ក្រោយពីពេលបានដេកតាំងសមាធិពេញមួយថ្ងៃ គ្នាហាក់មានកំលាំងពេញខ្លួន ព្រលឹងរបស់គ្នាហាក់បានដើបស្ទុះចេញពីសាកសពយ៉ាងរហ័ស ដូចជាផ្លេកបន្ទោល។ គ្នាបង្វែរខ្លួនសំលឹងទៅមើលសាកសពនោះ វាមិនមែនជារូបមុខមាត់របស់គ្នាទៀតទេ វាកំពុងតែហើមដូចជាចេកជោរ។ ពិតណាស់ដែលគ្នាមិនអាចចំណាំរូបនេះបាន។ សំលឹងបានបន្តិច គ្នាដែលកាលនោះនៅមានសំលៀកបំពាក់និងទទូរប៉ូបពណ៌សផងនោះ បានបណ្តែតខ្លួនចេញពីចេតិយដីយ៉ាងលឿនឆ្លេវ។

នៅពេលដំបូងដែលគ្នាចេញមកក្រៅ គ្នាពិតជាឆ្ងល់ជាពន់ពេក ព្រោះយប់ណាស់ទៅហើយចុះហេតុអ្វីបានជានៅមានមនុស្សម្នាដើរលេងក្នុងវត្តហាក់បីដូចជាមានពិធីបុណ្យទានដូចនេះ។

គ្នាបានហោះហើរទៅរកប្រភពសំលេងដែលនៅមិនឆ្ងាយពីផ្នូររបស់គ្នា។ មែនដូចជាគ្នាស្មាន មែនមានក្រុមមួយហ្វូងកំពុងតែនាំគ្នាលេងសប្បាយតែតាមពិតក្រុមនោះមិនមែនជាក្រុមមនុស្សនោះទេ វាគឺជាក្រុមខ្មោចបីសាចដែលត្រូវស្តេចយមរាជដោះលែងឲមកតាំងសមាធិដូចជាគ្នាដែរ។ នៅទីនោះ ចាន់ណារិនអ្ហើយ! គ្នាបានឃើញអស់ហើយនូវមនុស្សលោកទាំងឡាយដែលបានស្លាប់គ្រប់ប្រភេទមកក្លាយទៅជាខ្មោច។ រូបភាពរបស់ពួកគេបានបង្ហាញឲយើងដឹងថាគេបានស្លាប់ដោយរបៀបណា។ គ្នាបានឃើញខ្មោចម្នាក់មានសំណាមគ្រាប់កាំភ្លើងនៅលើថ្ងាស គ្នាពិតជាដឹងថាម្នាក់នោះប្រាកដជាស្លាប់ដោយសារគេបាញ់សំលាប់មិនខាន។ អ្នកខ្លះទៀតមានក្បាលក្រវិចក្រវៃតដោយសារតែត្រូវឡានបរកិនពីលើ។ ឯខ្លះទៀតរហែកសំពត់ខោព្រោះតែត្រូវបានគេរំលោភ ហើយក៏មានអ្នកខ្លះមានរូបរាងស្អាតបាតផងដែរនៅពេលដែលពួកនោះមិនបានប្រព្រឹត្តអំពើរបាបកាលពីគេនៅរស់។

នៅពេលដែល គ្នាបានហោះចូលទៅក្នុងចំណោមពួកគេ ទិដ្ឋភាពវាពិតជាមិនខុសពីឋានមនុស្ស





លោក ដែលមានអ្នកមានអ្នកក្រនោះប៉ុន្មានទេ តែគ្រាន់ថាអ្នកមានគេមានរូបល្អ ព្រោះតែគេបានសាងអំពើល្អកាលពីគេនៅរស់។

នៅក្នុងយប់ដ៏ងងឹតឈឹង មានតែពន្លឺពណ៌ប៉ៃតងខ្ចី ហ្វូងខ្មោចមានចំនួនជាច្រើនកុះករ។ វាហាក់បីដូចជាទីផ្សារឥចឹង មានលឺការជជែកគ្នាមិនចេះចប់។ ចំណែកឯខ្មោចក្មេងៗវិញនោះ បាននាំគ្នាហោះប្រជេញលេងពីមេឃឈើមួយទៅមេឃឈើមួយទៀត។ នៅតាមបណ្តោយផ្លូវដែលគ្នាបណ្តែតខ្លួនមើលគេនោះ គ្នាបានលឺមាត់អ្នកខ្លះនិយាយថាពួកគេនឹងទៅកើតនៅឯឋានសួគ៌ហើយអ្នកខ្លះទៀតក៏និយាយថានៅប៉ុន្មានថ្ងៃទៀតប៉ុណ្ណោះគេនឹងបានចេកចេញពីទីនេះទៅឋានថ្មីហើយ។ គ្នាហោះបណ្តើរគ្នាខំប្រឹងស្តាប់បណ្តើរ និងខំប្រឹងមើលពិសេសនោះ ខំរំពៃរកមនុស្សដែលធ្លាប់ស្គាល់ដែលគេបានស្លាប់មុនគ្នា តែគ្នាមិនបានជួបអ្នកណាម្នាក់សោះ។ ពួកគេគឺជាខ្មោចទាំងឡាយដែលបានមកដល់ទីនេះមុនគ្នា ហើយពួកគេនឹងចាកចេញទៅកើតឋានថ្មីនៅពេលបន្តបន្ទាប់គ្នា ពេលដែលពួកគេបញ្ចប់ការតាំងសមាធិគំរប់មួយរយថ្ងៃ តាមក្បួនច្បាប់ឋានក្រោមនោះ។

ទោះជាគ្នាមិនបានស្គាល់អ្នកណាម្នាក់ក៏ដោយ តែគ្នាហាក់មានសេចក្តីសប្បាយរីករាយនៅពេលដែលបានជួបពពួកខ្មោចទាំងនេះដែលកំពុងប្រព្រឹត្តសកម្មភាពផ្សេងៗគ្នា។ មានខ្លះទៅបានស្លាប់ទាំងគ្រួសារក៏មានដែរ តែភាគច្រើននៃពពួកខ្មោចទាំងនោះតែងតែស្លាប់ម្នាក់ៗឯងដូចជាគ្នាដែរ។ នៅពេលដែលបានមកដល់ទីនេះហើយ ទើបពួកគេទាំងចាស់ទាំងថ្មីចាប់ផ្តើមស្គាល់គ្នាជាហូហែរមក។

ជាការពិតណាស់ចាន់ណារិនឯងដឹងទេ? គ្នានិយាយមិនកុហកនោះទេ កាលនៅជាមនុស្សលោកយើងក៏ធ្លាប់មានសង្សារនិងគេដែរ ចំណែកឯឋានខ្មោចនេះវិញ ក៏មិនចាញ់ប៉ុន្មានដែរ។ មានគូរខ្មោចស្នេហាខ្លះ បានស្គាល់និងស្រលាញ់គ្នានៅក្រោយការស្លាប់របស់ពួកគេ។ ពួកខ្មោចទាំងនោះកាលបើរាត្រីស្ងាត់មកដល់ ពួកគេមិនបានមកចូលលេងក្នុងហ្វូងនិងគេទេ តែបែជានាំគ្នាពីរនាក់ទៅសំងំនៅគម្ពោតព្រៃទៅវិញ ឬក៏នៅក្នុងផ្នូរតែពីរនាក់ដើម្បីផ្តោះប្តូរមនោសញ្ចេតនា រវាងគ្នានិងគ្នា។ គ្រប់ៗខ្មោចដែលគ្នាបានឃើញនៅពេលនោះ មាត់ឲចចាច់មិនចេះដាច់ គ្នាមិនដឹងថាហេតុអ្វីបានជាពួកគេចូលចិត្តនិយាយម្លេះ។ សំរាប់គ្នាវិញ គ្នាមិនដឹងទៅនិយាយ

ជាមួយអ្នកណាទេ ព្រោះតែគ្នាមិនមានស្គាល់អ្នកណាម្នាក់សោះនោះ។ ទោះយ៉ាងនេះក្ដី គ្នានៅតែសប្បាយចិត្តព្រោះពេលនេះគ្នាចេះហោះហើរទៅតាមទំនើងចិត្តរបស់គ្នា។

នៅពេលដែលកំពុងសប្បាយនោះស្រាប់តែគ្នាបានលឺសំលេងមាន់រងាវ **«គូកៗៗគូក»** ។ កាលបើបានលឺសំលេងនេះភ្លាមបណ្ដាខ្មោចទាំងឡាយមិនថាប្រុសមិនថាស្រីពោះម៉ាយមេម៉ាយស្ទូម្បីតែគូរសង្សារកំពុងសារសងគ្នានោះ ក៏ត្រូវរត់ប្រសេចប្រសាច ហាក់បីដូចជាពួកគេបានដឹងថានឹងមានគ្រាប់បែកធ្លាក់ឥចឹង។ ម្នាក់ៗបើសិនជាមានកូនចៅនោះវិញ បានស្រែកឡើងទ្រហឹងអ៊ឹងកង ដើម្បីហៅពួកគេចូលមកកាន់ផ្ទះប្រចាំគ្រួសារវិញ។ តាមពិតទៅមេឃមិនទាន់ទាំងភ្លឺផង បើតាមតែគ្នាស្មានម៉ោងប្រមាណជាបួនព្រឹកប៉ុណ្ណោះ តែពួកគេបែជានាំគ្នាចូលអស់ទៅវិញ។ នៅពេលនោះគ្នាមិនបានបង្អែរបង្អង់ទេ គ្នាក៏បានបណ្ដែតខ្លួនចូលទៅក្នុងម្ឈូសរបស់គ្នាវិញដែរ។

នៅថ្ងៃបន្ទាប់មកដល់ទើបគ្នាចាប់ផ្ដើមមើលសៀវភៅធម៌ដែលលោកឧបរាជបានប្រគល់មកឲ។ ស្ទើរតែម្ភៃម៉ោងជារៀងរាល់ថ្ងៃដែលគ្នាត្រូវនៅតាំងសមាធិទន្និញធម៌ទាំងនេះ គឺចាប់ពីម៉ោងបួនព្រឹករហូតដល់ម៉ោងដប់ពីរអាធ្រាត ទើបគ្នាអាចចាកចេញមកក្រៅដកខ្យល់អាកាសបាន។ ថ្ងៃទីពីរនេះ វាពិតជាធ្វើឲគ្នាធុញទៅវិញ គ្នាអផ្សុកមែន តែដួងចិត្តរបស់គ្នាបានរលាយអស់ទៅហើយនូវការចង់បាន ការលោភលន់ឬព្យាបាទអ្នកដ៏ទៃនោះ។ នៅក្នុងចិត្តរបស់គ្នាមានតែសេចក្ដីអាណិត ប្រណីមេត្តាករុណាតែប៉ុណ្ណោះ។ គ្នាបានគិតថាខ្លួនរបស់គ្នាហាក់បីដូចជាខ្យល់ដែលកំពុងតែហោះហើរនៅលើអាកាសដ៏ធំល្វឹងល្វើយ។ គ្មានអ្វីដែលគួរឲគិតបារម្ភនោះទៀតទេ ព្រោះតែពេលនេះគ្នាបានមករស់នៅក្នុងសន្តិភាពរួចទៅហើយ។ នៅយប់នោះដែរ គ្នាមិនទៅមើលហ្វូងខ្មោចដែលចេញមកលេងបរិវេនវត្តនោះទេ គ្នាបានស្រូតបណ្ដែតខ្លួនតាមអាកាសសំដៅមកមើលដានិត គូដណ្ដឹងដ៏កំសត់របស់គ្នានៅឯផ្ទះរបស់នាង។ ជាពេលដែលគ្នាមានភាពស្រណោះសោកស្ដាយមកវិញនៅពេលដែលឃើញដានិតនៅលើកទីមួយបង្អស់ក្រោយពីពេលដែលគ្នាបានស្លាប់ទៅ ព្រោះតែមកដល់ថ្ងៃនេះទៅហើយនាងនៅតែមិនទាន់បាត់យំស្រណោះអាលោះអាល័យគ្នាទៀត។





គ្នាបានមកដល់បន្ទប់របស់នាង គ្នាមើលទៅម៉ោង ម៉ោងមួយយប់ទៅហើយ តែនាងនៅមិនទាន់បានគេងនៅឡើយទេ នាងកំពុងតែយំអោបរូបថតរបស់គ្នានៅជាប់និងទ្រូង។

នៅពេលដែលឃើញនាងដូចនេះហើយ ដែលអារម្មណ៍ស្ងប់របស់គ្នាបានរលាយអស់ គ្នាបានស្រក់ទឹកភ្នែកដោយមិនដឹងខ្លួនតាមនាងដែរ។ គ្នាមើលទៅនាងទាំងខ្លោចចិត្តជាទីបំផុត។ នៅពេលនោះគ្នាបានភ្លេចខ្លួនហើយនិយាយទៅនាងថា៖

**«កុំយំណាពៅណា! បងទៅបានសុខហើយ!»**

នាងមិនឆ្លើយនិងគ្នាទេតែបែរជាយំបន្តទៅវិញ។ គ្នាបានបន្តទៀតថា៖

**«អូនកើតទុក្ខធ្វើអ្វី បើយើងបានធ្វើកម្មនិងគេមុន ហើយឥឡូវនេះគេមកយកទោសពីយើងវិញនោះ ឈប់យំទៅណា! យើងគង់តែជួបគ្នាវិញទេតើ»**

គ្នាមកអង្គុយនៅក្បែរគ្រែហើយយកដៃមកអង្អែលសក់របស់នាង។ គ្នានិយាយតែម្នាក់ឯងរហូតដល់តែគ្នាបានដឹងខ្លួនថា អ្វីដែលគ្នាកំពុងតែលួងលោមនោះ នាងមិនអាចស្ដាប់លឺអ្វីទាំងអស់។ គ្នាបានដឹងថានាងទទួលភាពត្រជាក់ពីគ្នានៅពេលដែលគ្នានៅជិតនាង ដូចនេះហើយបានជាគ្នាសុខចិត្តហោះមកសំកាំងខ្លួននៅពីចំងាយនាងទៅវិញដោយទុកឲនាងប្រឹងសំងំគេង។ នៅយប់នោះនាងគេងបិតភ្នែងឈឹង នាងគេងបែរមុខទៅនិងជញ្ជាំងតែនាងមិនបានដឹងថាគ្នាកំពុងតែសំលឹងមើលនាងនៅខាងក្រោយដោយសេចក្ដីអាណិតស្រលាញ់ជាពន់ពេកនោះទេ។ រូបដ៏ខៀវស្រងាត់របស់គ្នាបាននិងកំពុងបណ្ដែតខ្លួននៅក្នុងបន្ទប់ដ៏ស្ងាត់របស់នាង។ គ្នាបានក្លាយទៅជាខ្មោចទៅហើយ តើគ្នាមានសមត្ថភាពអ្វីទៅថែរក្សានិងផ្ដល់សុភមង្គលដល់នាងទៀត? គ្នាសួរខ្លួនឯងតើគួតែគ្នាយកនាងទៅជាមួយគ្នាឬ? ទេ! គ្នាមិនអាចធ្វើដូចនេះបានទេ? ព្រោះវាខុសទៅនិងច្បាប់ភពថ្មី ហើយម្យ៉ាងវិញទៀតគ្នាក៏គង់តែបានជួបនាងនៅជាតិខាងមុខនេះដែរ តើមានហេតុផលអ្វីដែលគ្នាគួរតែធ្វើអំពើនេះ? គ្នាគ្រវីក្បាលដោយស្ដាយស្ដាយថាពីរនាក់គ្នាមិនអាចបន្តរស់នៅជាមួយគ្នាបានបន្តិចទៀត។

នៅយប់នោះគ្នាបាននៅមើលនាងរហូតដល់នាងគេងលក់។ គ្នាបានព្យាយាមហៅដួងព្រលឹងនាងឲចេញពីខ្លួនមកជួបនិងគ្នា នឹងអាលគ្នាបានរៀបរាប់ប្រាប់នាងថា គ្នាមានសេចក្ដីសុខទុក្ខជាធម្មតាទេ កុំឲនាងមានការបារម្ភនិងគ្នាធ្វើអ្វី ហើយឲនាងប្រឹងធ្វើបុណ្យដាក់ទាន ពិសេសនោះគឺត

ពីអនាគតរបស់នាងជាមួយអ្នកផ្សេង អ្នកដែលនាងគិតថាល្អនិងចេះយកចិត្តទុកដាក់និងនាង។ មិនយូរប៉ុន្មាននោះទេ នៅពេលដែលនាងអស់កម្មវេរានៅឯឋានមនុស្សលោកពីរនាក់យើងនៅតែបានជួបគ្នាទេ។

នៅពេលនោះគ្នាបានខំអញ្ជើញព្រលឹងនាងមកក្រៅ តែដោយសារនាងអត់ងងុយជាច្រើនថ្ងៃណាស់មកហើយ ដួងព្រលឹងរបស់នាងមិនព្រមទទួលការអញ្ជើញរបស់គ្នានោះទេ។ គ្នានៅមើលនាងរហូតដល់ម៉ោងបួនកំណត់ទើបគ្នាត្រលប់មកកាន់ផ្នូរតាំងសមាធិវិញដោយនៅតែមានចិត្តអាណិតនាងជាក្រៃលែង។

ចាប់តាំងពីពេលនោះមក ទោះគ្នាមិនបានចំណាយពេលច្រើន តែស្ទើររៀងរាល់យប់គ្នាតែងបានទៅមើលនាងគេង មើលនាងនៅកន្លែងធ្វើការ ពេលដែលនាងត្រូវបំពេញការងារពេលយប់ជារឿយៗ ហើយតែងបានពន្យោសពនាងផងដែរ តែគ្នាមិនបានដឹងថានាងបានទទួលសុបិន្តទទួលសាររបស់គ្នាដែរឬទេ។

នៅថ្ងៃមួយនៅពេលដែលគ្នាបានចេញពីផ្ទះដានិត គ្នាបានបណ្តែតខ្លួនទៅលេងជាតាសង្ក្រារបស់ពួកម៉ាកឯង។ នៅពេលដែលគ្នាទៅដល់មុខផ្ទះនាង ម្ចាស់ជំនៀងផ្ទះរបស់គេមិនព្រមឲគ្នាចូលលេងនឹងនាងទេ ព្រោះតែគ្នាមិនមានការអនុញ្ញាត្តិពីម្ចាស់ផ្ទះ។ គ្នាបានអង្វរទៅលោកជំនាងផ្ទះតែគាត់នៅតែមិនព្រមដោយគាត់បានប្រាប់មកគ្នាវិញថា មានកូនក្មេងនៅខាងក្នុងកំពុងតែមានជំងឺ ហើយបើគ្នានៅតែចូលទៀតនោះ កូនក្មេងនោះនឹងមានជំងឺរហូតប៉ះពាល់ដល់ជីវិតមិនខាន ព្រោះតែភាពដ៏ត្រជាក់របស់គ្នា។ គ្នាទទួលយល់ព្រមការពន្យល់របស់គាត់ហើយយល់ព្រមមិនចូលទៅក្នុងផ្ទះទេ។ គ្នាឈរនៅខាងក្រៅ ហើយបានហៅព្រលឹងជាតាចេញតែនាងមិនព្រមមកសោះ។ គ្នាមិនដឹងដែរប្រហែលជានាងមិនចង់ជួបគ្នាទៀតទេ ហើយក៏ប្រហែលជានាងមិនចង់ទៅញ៉ាំគុយទាវជាមួយគ្នាដែរ។ គ្នាបានត្រឹមតែសំលឹងពីខាងក្រៅ រួចបន្ទាប់មកទើបគ្នាត្រលប់មកកាន់ផ្នូររបស់គ្នាវិញ។

ថ្ងៃទីបីនៃការមកដល់ទីនេះ ទីដែលគ្នាត្រូវតាំងសមាធិ គ្នាបានទទួលអារម្មណ៍ថាចាន់ណារិនឯងត្រលប់មកប្រទេសខ្មែរយើងវិញដើម្បីមកមើលផ្នូរគ្នា។ នៅពេលនោះគ្នាពិតជាមានសេចក្តី





រីករាយជាពន់ពេក ហើយនៅវេលាម៉ោងប្រមាណជាដប់ពីរថ្ងៃត្រង់ នៅពេលដែលគ្នាបានលឺសំលេងយន្តហោះរបស់ពួកម៉ាកឯងហោះកាត់ផ្នូររបស់គ្នានោះ ធ្វើឲគ្នាតាំងសមាធិមិនចូលឡើយ។ គ្នាងើបអង្គុយដកដង្ហើមធំតែម្នាក់ឯង។ គ្នាស្រក់ទឹកភ្នែកនៅក្នុងផ្នូរ គ្នាដឹងយ៉ាងច្បាស់ថាពេលនេះពួកម៉ាកឯងនឹងក្រៀមក្រំក្នុងចិត្តមិនខានព្រោះធ្លាប់តែគ្នាទៅទទួលគ្រប់ពេល តែពេលនេះមិនមានវត្តមានរបស់គ្នានៅឈររងចាំឯព្រលានយន្តហោះទៀតទេ។ តើពួកម៉ាកឯងនឹងកំសត់ក្នុងចិត្តយ៉ាងណា? គ្នាកាន់តែគិតពីពួកម៉ាកឯង ទឹកភ្នែករបស់គ្នាកាន់តែហូរ គ្នាស្រែកយំតែម្នាក់ឯងនៅក្នុងផ្នូរ។ ការសោកស្តាយដែលគ្នាបានបំភ្លេចនោះ ពេលនេះបានត្រលប់មកវិញទាំងអស់។ ត្រូវហើយពេលនោះគ្នាស្តាយណាស់ ស្តាយមិនបានឃើញមុខគ្នាឲបានយូរជាងនេះទៀត។ គ្នាយំទួញសោកតែម្នាក់ឯងហើយបន់ឲយប់និងអាលគ្នាបានទៅជួប ពួកម៉ាកឯង។

ក្រោយពីទួញសោកមួយសន្ទុះធំមក គ្នាក៏ខិតខំប្រឹងសំងំតាំងសមាធិបន្តទៅទៀត តែគ្នាពិតជាតាំងមិនចូលទាល់តែសោះ។ អារម្មណ៍គ្នាមួយបានគិតថាចាន់ណារិនឯង នឹងមកលេងផ្នូររបស់គ្នានៅថ្ងៃនេះនៅឯវត្តសុភាឃួនដែលនៅក្បែព្រលានយន្តហោះមិនខាន តែអារម្មណ៍មួយទៀតគិតថាពួកម៉ាកឯងមិនស្គាល់វត្តនេះទេហើយក៏មិនអាចមកបានដែរ។ គិតនៅត្រង់ពីរចំណុចនេះគ្នាតាំងសមាធិលែងចូលទៀតហើយ គ្នាងើបអង្គុយឈ្ងរ នឹកស្រម៉ៃទៅអនុស្សាវរីយ៍រាប់ម៉ឺនជំពូកដែលពួកយើងបានសាងរួមគ្នា។

ចាន់ណារិនឯងមានដឹងទេ? នៅថ្ងៃដំបូងដែលពួកម៉ាកឯងបានមកដល់ស្រុកខ្មែរ នៅយប់នោះម៉ោងប្រមាណជាដប់ពីរអាធ្រាត គ្នាបានបណ្តែតខ្លួនចូលទៅក្នុងបន្ទប់ឯង។ គ្នាឃើញចាន់ណារិនឯងសប្បាយណាស់ ហើយគ្នានឹកចាន់ណារិនឯងណាស់។ គ្នាដេកអោបចាន់ណារិនឯង គ្នាចាក់ក្រឡេក តែពួកម៉ាកឯងដេកធ្វើហីហាក់បីដូចជាគ្នាមិននៅទីនោះឥចឹង។ គ្នាពិតជារីករាយ នៅពេលដែលបាននៅជិតពួកម៉ាកឯងដូចនេះ។ ម៉ោងប្រម៉ាណជាពីរយប់ចាន់ណារិនឯងមានចាំទេថា ចាន់ណារិនឯងបានភ្ញាក់ដឹងខ្លួន ហើយបើកភ្នែកព្រឹមៗដោយសារតែមានភាពត្រជាក់ខ្លាំងពេក។ គ្នាដឹងថាពួកម៉ាកឯងរងារ ហើយគ្នាគួរតែចេញទៅទុកឲ ពួកម៉ាក